# សិទ្ធិរបស់ស្ត្រី

៙❀៚

ដោយ

អ្នកស្រី អ៊ុង តារាវិចិត្រ ចាយ

លោកស្រី អ៊ឹង មឹង ឡាមីញ៉ៀល

ឧបាសិកា ឌី សាមាវ៉ាន់

លោកស្រី មាស សេដ្ឋា ភរិយា លោក ឌុក រ៉ាស៊ី


បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

ដោយ ពុទ្ធបរិស័ទ វត្តពោធិវង្ស

ប្រទេសបារាំង

ព.ស. ២៥៥៧ គ.ស. ២០១៤

# អារម្ភកថា

៙៚៙

ធម្មជាតិ បង្កើតឲ្យមានមនុស្ស ប្រុស ស្រី ដើម្បីគេរួមរស់នៅជាមួយគ្នា និង ដើម្បីគេបង្កើត កូន ចៅ បន្តពូជពង្ស យូរអង្វែងទៅ ។ ធម្មជាតិ បើក សិទ្ធិ សេរីភាព ឲ្យមនុស្សរស់នៅដូច ៗ គ្នា ស្មើ ៗ គ្នា មិនមានកំណត់លក្ខណ៍ខណ្ឌអ្វីទេ ដើម្បីគេបានសុខសប្បាយទាំងអស់គ្នា ។ ការកំណត់ ព្រំដែន សិទ្ធិ សេរីភាព ជារឿងដែលមនុស្សគ្នាឯង ទើបនឹងធ្វើឡើងខាងក្រោយ ។

ខ្ញុំ មិនចង់ឃើញ មិនចង់ឮ រឿងមនុស្ស ប្រុស ស្រី ប្ដី ប្រពន្ធ ឈ្លោះគ្នា ប្រមាថមើលងាយគ្នា វាយធ្វើបាបគ្នា ទេ ។ ព្រោះគេជាមាតាបិតា អ្នកបង្កើតសត្វលោក អ្នកចិញ្ចឹមថែរក្សាសត្វលោក អ្នកសាងសេចក្ដីត្រជាក់ត្រជុំក្សេមក្សាន្តដល់សត្វលោក ។ គេត្រូវតែស្រឡាញ់រាប់អានគ្នា គោរព លើកតម្កើងគ្នា និង រស់នៅយ៉ាងសុខដុមរមនា ជាមួយគ្នា ។ អាស្រ័យហេតុនេះ ទើបខ្ញុំ នាំគ្នាធ្វើសិក្ខាសាលា ប្រធានបទ សិទ្ធិរបស់ស្ត្រី នេះឡើង ។

សព្វថ្ងៃ ក្នុងពិភពលោក ស្រី ៗ ច្រើនប្រទេសណាស់ មិនទាន់មាន សិទ្ធិ សេរីភាព សមរម្យនៅឡើយ សូម្បីប្រុស ៗ ក៏មិនទាន់មានសិទ្ធិ សេរីភាព គ្រប់គ្រាន់ដែរ ។ ដូច្នេះ គេត្រូវតែរួមគ្នាទាមទារ សិទ្ធិ សេរីភាព តទៅទៀត រហូតទាល់តែបានសម្រេច

ជាស្ថាពរ ។ ពេលណាគេបានទទួលសិទ្ធិ សេរីភាព សព្វគ្រប់ ហើយ គេត្រូវយកវាទៅប្រើឲ្យថ្លៃថ្នូរ និង ប្រើកុំឲ្យខូចប្រយោជន៍រួម ។ ខ្ញុំ សូមជម្រាបថា ការរួចផុតពីអំពើជិះជាន់ ហើយបានទទួលសិទ្ធិ សេរីភាព អំពីមនុស្សផងគ្នា ជាការល្អហើយ ប៉ុន្តែមិនទាន់ប្រសើរទេ ។ គេត្រូវតែរំដោះខ្លួនឲ្យមានសិទ្ធិ សេរីភាពផុតពីអំណាចនៃកិលេស អវិជ្ជា តណ្ហា ជាដើមទៀត ទើបចាត់ទុកថា ជាការប្រសើរសព្វគ្រប់ ដោយប្រការទាំងពួង ។

ខ្ញុំ សូមថ្លែងអំណរគុណចំពោះលោកស្រីវាគ្មិនទាំង ៤ នាក់ ដែលបានអញ្ជើញមកជួយដោះស្រាយ អធិប្បាយបំភ្លឺ នូវ សិទ្ធិ របស់ស្រី ក្នុងវិស័យផ្សេង ៗ យ៉ាងពីរោះក្បោះក្បាយ និង សូមថ្លែងអំណរគុណផងដែរដល់លោក អ្នក ទាំងអស់ ដែលបានជួយធ្វើឲ្យសិក្ខាសាលានេះប្រព្រឹត្តទៅបានជោគជ័យ ។ ក៏ប៉ុន្តែ ខ្ញុំ សូមអភ័យ-ទោសផង ដែលបានខកខានអស់ច្រើនឆ្នាំ ពុំបានចាត់ការបោះពុម្ព និងសូមថ្លែងអំណរគុណ ជាពិសេសចំពោះ ភិក្ខុ ពេជ្រ សាម៉ុន ចិរវឌ្ឍោ ចៅអធិការវត្តពោធិវង្ស ប្រទេសបារាំង និង លោក អ្នក ទាំងអស់ ដែលបានជួយចាត់ចែងរៀបចំបោះពុម្ព ឲ្យកើតជាកូនសៀវភៅនេះឡើង ក្នុងឱកាសនេះ ។ ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបានជាប្រយោជន៍ខ្លះដល់លោក អ្នក អានជាពុំខាន ៕

ខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសល ដែលកើតពីក្ងួនសៀវភៅនេះ ជូនចំពោះវិញ្ញាណ នៃ បុព្វបុរសខ្មែរទាំងឡាយ និង ជូនចំពោះវិញ្ញាណ នៃ បុព្វការី និង ញាតិមិត្រ នៃ យើងទាំងអស់គ្នា ដែលលោកបានចែកឋានទៅហើយ ។ សូមវិញ្ញាណទាំងឡាយនោះអនុមោទនា ទទួលយកនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត កុំបីខាន ។

វត្តពោធិវង្ស ថ្ងៃទី ០១ មករា ឆ្នាំ ២០១៤

ភិក្ខុ ឆិន ភេន ឥន្ទបញ្ញោ

នមត្ថុ រតនត្តយស្ស

៣ ✻ ៧

# សិទ្ធិរបស់ស្ត្រី

# សិទ្ធិ និង ទំនៀមទម្លាប់របស់ស្ត្រី ក្នុងអតីតកាល

ដោយអ្នកស្រី អ៊ុង តារាវិចិត្រ ចាយ

១៣✱៨

សិទ្ធិ យើងមានតាំងតែពីពេលដែលយើងរាល់រូប បានចូលមកចាប់កំណើត នៅក្នុងផ្ទៃម្ដាយម្ល៉េះ ។ យើងមានសិទ្ធិស្មើគ្នាទាំងអស់ គ្រាន់តែថា ខុសគ្នាពី ភេទ ស្មារតី និង មានទេពកោសល្យ ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។

អ្នកគ្រប់គ្រងរដ្ឋនីមួយៗ ត្រូវតែទទួលការខុសត្រូវ ទៅលើជីវិត និង អនាគតរបស់ប្រជាពលរដ្ឋ ។ ត្រូវបង្កើតច្បាប់ ការពារគ្រប់គ្រង គោរពសិទ្ធិ ដើម្បីឲ្យប្រជាជនទូទៅមានជីវិតរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរ សុខ-សន្តិភាព មានយុត្តិធម៌ និង មានសេរីភាព ។

## សិទ្ធិស្ត្រីនៅប្រទេស ឥណ្ឌា[១]

អ្នកកាន់អំណាច និង គ្រប់គ្រងរដ្ឋ នៅប្រទេសឥណ្ឌា សុទ្ធសឹងតែជាអ្នកកាន់ព្រហ្មញ្ញសាសនា ទាំងអស់ បានបង្កើតច្បាប់មួយស្ដីពីការរើសអើងរវាងបុរស និង ស្ត្រី ។

យោងទៅតាមតម្លៃមនុស្ស និង តម្លៃច្បាប់ ស្ត្រីគ្មានសិទ្ធិអ្វី

---

១ http://213.41.195.108:8080/ecjs/coes3/femmeinde.htm

ស្មើនឹងបុរសទេ ។ ពួកព្រាហ្មណ៍បានបញ្ជាក់ច្បាស់ណាស់ថា ស្ត្រីត្រូវតែនៅក្រោមចំណុះបុរសគ្រប់ជាន់ថ្នាក់ ។ ស្ត្រី គ្មានច្បាប់ គ្មានលក្ខន្តិកៈ និង ទទួលតំណែង ឬ វណ្ណៈណាមួយឡើយ នៅក្នុងសង្គម ឬ នៅក្នុងគ្រួសារ គឺរស់ត្រឹមតែទាសីប៉ុណ្ណោះ ។ ជួនកាលទៀត ត្រូវគេបង្ខំរំលោភភេទ ឬក៏ គេទុកដូចជារបស់អ្វីមួយសម្រាប់យកទៅភ្នាល់ នៅក្នុងវង្វង់ល្បែងទៀតផង ។

គ្មានច្បាប់ណាមកជួយការពារ ឬ ធានាពីសិទ្ធិរបស់ស្ត្រីទេ តាំងពីកើត រហូតដល់ពេលមានប្តី មានកូន និង រហូតដល់បាត់បង់ជីវិត ។

វង្សត្រកូលគ្រួសារឥណ្ឌា ប្រាថ្នាចង់បានតែកូនប្រុស ដើម្បីមើលថែរក្សាឪពុក ម្តាយ និង ជាពិសេសបំផុតនោះ គឺការទទួលមរតកតំណែលពីដូន-តា ដូចជាដីស្រែ ឬ ដីធ្លី ជាដើម ។ ភាគច្រើនណាស់ ដែលវង្សត្រកូលគ្រួសារឥណ្ឌា មិនចង់បានកូនស្រីព្រោះគេយល់ថា ជាអពមង្គល ឬក៏ ត្រូវទទួលបណ្តាសា ។ កូនស្រី កើតមកគ្មានប្រយោជន៍អ្វីដល់គ្រួសារទេ ។ តាមស្ថិតិ ទារកដែលម្តាយបង្ខំយកចេញពីផ្ទៃ មានអត្រាកម្រិតខ្ពស់ណាស់ ក្នុងមួយឆ្នាំ ។ ពេលណាដែលដឹងថាកូននៅក្នុងពោះនោះជាកូនស្រី ។

កូនស្រីខ្លះដែលកើតមកហើយ ត្រូវគ្រួសារសម្លាប់ភ្លាម ក៏មានចំនួនច្រើនណាស់ដែរ ។

កូនស្រីត្រូវឋិតនៅក្រោមអាណាព្យាបាលឪពុក ។ ការអប់រំទៅរៀនសូត្រនៅសាលា មិនមែនជាការចាំបាច់ជាចំបងទេ កូនស្រីខ្លះត្រូវទៅរកការធ្វើនៅក្រៅផ្ទះ ឬ ធ្វើការក្នុងផ្ទះបំរើគ្រួសារ ។ មិនបានរៀនសូត្រខ្វះការអប់រំ កូនស្រីមិនអាចចេះគិតពិចារណាដេញរកហេតុផល និង ទទួលការបណ្តុះវិជ្ជាទៅលើមុខងារ ការណាមួយសម្រាប់អនាគតរបស់ខ្លួន ដែលអាចឲ្យរស់នៅបានដោយមិនចាំបាច់ពឹងផ្អែកទៅលើឪពុក ឬ ប្តី ទេ ។

៤៦% ក្នុងចំណោមកូនស្រី អាយុពី២០ ទៅ ២៤ ឆ្នាំ ឪពុកម្តាយ បានរៀបការឲ្យមានស្វាមីហើយ ។ កូនស្រីខ្លះទៀត មុនអាយុ ១៨ ឆ្នាំ ឲ្យទៅធ្វើជាស្រីកំណាន់ ដើម្បីគេចផុតពីគ្រោះថ្នាក់រំលោភភេទ ។ កូនស្រីខ្លះទៀត ចាប់ពីអាយុ ៨ ឆ្នាំទៅ ត្រូវឪពុកម្តាយ បង្ខំឲ្យទៅលក់ខ្លួនតាមចិញ្ចើមថ្នល់ ដើម្បីសម្រួលស្ថានភាពគ្រួសារ ដោយពុំបានគិតពីគ្រោះថ្នាក់រងទុក្ខវេទនា និង ជម្ងឺដែលកូនស្រីទាំងអស់នោះបានទទួលឡើយ(២) ។

បើកូនស្រីនៅក្មេង អាយុមុន ១៨ ឆ្នាំ ឪពុក-ម្តាយ មិនសូវអស់ប្រាក់ជំនូនទៅលើឪពុក-ម្តាយ ខាងប្រុសទេ ។ ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ឪពុក-ម្តាយ ខាងស្រីត្រូវធានា ទទួលរ៉ាប់រង

---

(២) -Droit des femms (Rappot ONU , fraternet.com

ចំណាយទាំងអស់ ។ គ្រួសារខ្លះជាប់ជំពាក់ប្រាក់បំណុលដ៏ធ្ងន់ធ្ងរ ពិបាកណាស់ នឹងរកប្រាក់មកដោះសងបំណុលគេ មិនដឹងដោះស្រាយដោយវិធីណា ។ ព្រឹទ្ធភាសិតមួយបានចែងថា "ការចិញ្ចឹមកូនស្រី ហាក់បីដូចជាស្រោចដំណាំ ឬ ស្រោចសួនច្បារ របស់អ្នកជិតខាងទៅវិញ" ។

ទើបតែមកដល់ឆ្នាំ ១៩៥៥ រដ្ឋាភិបាលឥណ្ឌា បានលុបបំបាត់ចោលនូវទំនៀមទម្លាប់ស្តីពីទម្ងន់នៃជំនូនឪពុក-ម្តាយ ខាងស្រីទៅលើឪពុក-ម្តាយ ខាងប្រុស ។

ក្រោយពីរៀបមង្គលការមក ស្ត្រីខ្លះ ក៏នៅតែទទួលទុក្ខទារុណកម្មពីគ្រួសារខាងប្តី គំរាមកំហែង រហូតដល់ស្លាប់ក៏មានដែរ ដោយសំអាងទៅលើប្រាក់ជំនូនពីខាងស្រី ប្រគល់មកមិនគ្រប់គ្រាន់ សមល្មមនឹងពិធីរៀបមង្គលការ ។

គេវាយតម្លៃឃើញ មានការសម្លាប់ស្ត្រីប្រមាណ ៦០០០ នាក់ក្នុងមួយឆ្នាំ ។ ថ្វីត្បិតតែរដ្ឋាភិបាល បានលុបច្បាប់តាំងពីឆ្នាំ ១៩៥៥ មក ស្តីពីជំនូនក្នុងពិធីរៀបមង្គលការនេះ ។

ទើបមកដល់ខែសីហា ឆ្នាំ ២០០៥ បានរដ្ឋសភាអនុម័តបន្ថែមប្រកាសការពារសិទ្ធិស្ត្រី ហាមឃាត់មិនឲ្យប្រព្រឹត្តអំពើឃោរឃៅពីប្តី និង ពីគ្រួសារខាងប្តី ។

ប្រសិនណាបើប្តីទទួលមរណភាព ប្រពន្ធត្រូវលោតចូល

ទៅក្នុងភ្លក់ភ្លើង នៅពេលដែលគេប្រារព្ធបូជាសពប្ដី ។

ភរិយាត្រូវនៅក្រោមអាណាព្យាបាលឪពុកមា ខាងឪពុក បើគ្មានទេ ត្រូវឋិតនៅក្រោមអាណាព្យាបាល អ្នកកាន់អំណាចរបស់រដ្ឋ ។

ក្នុងឆ្នាំ ១៨៧៦ រដ្ឋាភិបាលប្រទេសអង់គ្លេស បានថ្វាយកិត្តិយស ព្រះមហាក្សត្រិយានី វិក្ទូរីយ៉ា (Victoria) ជារាជាធិរាជិនី (Impératrice des Indes) នៃប្រទេសឥណ្ឌា ។

ក្នុងឆ្នាំ ១៩១៤ លោក មូហង់ដាស ការ៉ាំចន្ទ គ្គង់ឌី (Mohandas Karamchand Gandhi) សម្រេចចិត្តទាមទារយុត្តិធម៌ និង សេរីភាព ព្រោះមិនព្រមឲ្យប្រទេសអង់គ្លេស ចម្រាញ់យករូបធាតុដើមរបស់ប្រទេសឥណ្ឌា ទៀត ។

រួមជាមួយនឹងសហការីរបស់លោកម្នាក់ឈ្មោះ យ៉ាវ៉ាហាឡាល់ នេរុ (Jawaharlal Nehru) បានណែនាំប្រជាពលរដ្ឋ ឲ្យមានការតស៊ូអត់ធ្មត់ មានចរិតអង់អាច ប្រកបដោយអំពើអហឹង្សា បង្ហាញភាពស្មោះត្រង់ សេចក្ដីថ្លៃថ្នូរ និង យុត្តិធម៌របស់ប្រជាជនឥណ្ឌា ចំពោះប្រទេសជាតិ ។

ប្រកបដោយមិត្តភាពដ៏ខ្ពង់ខ្ពស់ និង ការទុកចិត្តយ៉ាងកក់ក្ដៅរវាងលោកទាំងពីរ លោក ហ្វេរូស៊ិ គ្គង់ឌី (Feroze Gandhi) ជាកូនប្រុសរបស់លោក គ្គង់ឌី (Gandhi) បានរៀបអាពាហ៍ពិពាហ៍

ជាមួយនាង អ៊ិនឌីរ៉ា ព្រិយាដារស្ស៊ីនី (Indira Priyadarshini) ជាកូនស្រីលោក យ៉ាវ៉ាហាឡាល់ នេរូ (Jawaharlal Nehru) ក្នុងឆ្នាំ ១៩៤២ ។

លោកស្រី អ៊ិនឌីរ៉ា ព្រិយាដារស្ស៊ីនី (Indira Priyadarshini) ខិតខំព្យាយាមយ៉ាងមុតមាំជាមួយស្វាមី ពន្យល់បង្ហាញដល់ប្រជាជនឥណ្ឌា ទាំងប្រុសទាំងស្រី ឲ្យមានលក្ខណសម្បត្តិ សមរម្យប្រពៃ មានការចេះដឹង ចេះយល់ពីបញ្ហាប្រទេសជាតិ ។ ក្នុងចំណង់ថែរក្សាឲ្យប្រទេសមានការចំរើនលូតលាស់ មានវឌ្ឍនភាព សន្តិភាព លោកស្រីបានយកចំណេះ ដែលលោកស្រីធ្លាប់បានទៅរៀនសូត្រនៅប្រទេសស្វ៊ីស (Suisse) និង អង់គ្លេស (Anglais) ពីអាយុ ១៧ ឆ្នាំ ។

ចាប់ពីពេលនោះមក ស្ត្រីចាប់ផ្តើមអំពាវនាវសុំរដ្ឋាភិបាលទទួលស្គាល់តម្លៃស្ត្រី និង ប្រគល់សិទ្ធិឲ្យស្ត្រីផង ។

ប្រទេសអង់គ្លេស ព្រមប្រគល់ឯករាជ្យ ឲ្យទៅប្រជាជនឥណ្ឌាវិញ នាថ្ងៃទី ១៥ ខែសីហា ឆ្នាំ ១៩៤៧ បន្ទាប់ពីការត្រួតត្រាអស់រយៈ ១៩៧ ឆ្នាំមក “១៧៥០-១៩៤៧” ។

លោក មូហាង់ដាស ការ៉ាំចន្ទ គន្ធី (Mohandas Karamchand Gandhi) បានទទួលនូវការគ្រប់គ្រង និង ទទួលខុសត្រូវទាំងស្រុង ទៅលើប្រទេសឥណ្ឌា ទាំងមូល ។

រហូតមកដល់ថ្ងៃទី៣០ ខែមករា ឆ្នាំ ១៩៤៨ គេបានធ្វើឃាតកម្មមកលើរូបលោក នៅពេលដែលលោកកំពុងធ្វើដំណើរទៅសួត្រធម៌ ។

លោក យ៉ាវ៉ាហាឡាល់ នេរូ (Jawaharlal Nehru) ត្រូវទទួលតំណែងជាអ្នកគ្រប់គ្រងរដ្ឋជាបន្ត ។

នាថ្ងៃទី ២៧ ខែឧសភា ឆ្នាំ ១៩៦៤ លោក នេរូ (Neru) ទទួលមរណភាព លោកស្រី អ៊ិនឌីរ៉ា ព្រិយាដារស៊ីនី (Indira Priyadarshini Gandhi) ក៏ទទួលមុខតំណែងការងារ ។

រហូតមកដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៨៤ អ្នកដែលលោកស្រី ទុកចិត្តឲ្យដើរតាមជួយការពារសន្តិសុខលោកស្រី បានក្បត់ធ្វើឃាតលោកស្រីនៅក្នុងសួនច្បារ របស់លោកស្រីផ្ទាល់តែម្តង ។

ការធ្វើឃាតនេះ មិនមែនមកពីទម្លាប់រើសអើងប្រឆាំងភេទឬស្អប់ស្ត្រីទេ គឺបណ្តាលមកពីបញ្ហានយោបាយ ។



មហាក្សត្រិយានី វិក្តូរីយ៉ា
(១៨១៩ - ១៩០១)





លោក មូហាន់ដាស ការ៉ាំចន្ទ គន្ធី និង ភរិយា



លោក ជវាហាឡាល់ នេរុ និង លោក មូហាន់ដាស ការ៉ាំចន្ទ គន្ធី
(១៨៨៩ - ១៩៦៤) (១៨៦៩ - ១៩៤៨)



លោក ហ្វេរូស គន្ធី លោកស្រី អ៊ិនឌីរ៉ា ព្រិយាដារស្ស៊ីនី
(១៩១៧-១៩៨៤)

## សិទ្ធិ ស្ត្រី នៅប្រទេស ចិន(៣)

កាលដើមឡើយ ពីមួយពាន់ឆ្នាំមុននោះ សង្គមចិន ទាំងមូល មានទម្លាប់មិនចូលចិត្តស្រី គឺផ្ដិតជាប់ជានិច្ចក្នុងអារម្មណ៍ សតិស្មារតីរបស់បុរសថា ស្រីគ្មានសមត្ថភាព និង ទទួលការអប់រំ គ្មានគំនិត មិនឆ្លាត ហើយនៅក្នុងជម្រៅស្ត្រីនោះ មានតែភាពអាក្រក់ មិនយល់អ្វីទាំងអស់ ។

ស្ត្រី កើតមកសម្រាប់តែនៅបំរើបុរស បំរើគ្រួសារ និង សម្រាប់បង្កើតកូន ។

មានភាសិតសាមញ្ញច្រើនណាស់ បានសរសេរទុកជាសាក្សីថា "ស្រីរូបល្អ ឆ្លាត គឺដូចសត្វមៀម ដែលនាំចង្រៃ និង ជូននាំឲ្យមានគ្រោះថ្នាក់" ហើយបញ្ជាក់បន្ថែមថា "បើកាលណាស្រីនិយាយរក គ្រាន់តែញញឹមបានហើយ តែកុំឆ្លើយតប" ។

ស្ត្រី មានការឈឺចាប់រងគ្រោះ អត់ទ្រាំ អត់ធ្មត់ ពីការរើកញែករើសអើងភាពមិនស្មើគ្នាគ្រប់បែបយ៉ាង រវាងបុរស និង ស្ត្រី ដែលមាននៅក្នុងគ្រួសារ នៅក្នុងសង្គម ។

ស្ត្រី មិនបានទទួលការអប់រំ ឬ ស្គាល់វប្បធម៌ទេ គឺគ្មានលក្ខន្តិកៈអ្វីចែងទុកជា លក្ខណៈស្ត្រី នៅក្នុងសង្គមឡើយ ។

---

(៣)-Orientale.fr. La femme dans la société chinoise ancienne

ម្ដាយខ្លះដែលមានកូនស្រីមកច្រើនហើយ នាពេលកំណើតកូនស្រីក្រោយមក ដាច់ចិត្តយកកូនទៅចោលនៅតាមភ្លឺស្រែ ពេលយប់ហាលភ្លៀងខ្យល់ នាំឲ្យសត្វសាហាវមកខាំសម្លាប់ដោយគ្មានវិប្បដិសារី សោកស្ដាយបន្តិចសោះឡើយ ។

ចិត្តជាម្ដាយ ស្រឡាញ់កូនមិនរើសភេទនោះ មិនអាចប្រឆាំងនឹងអំណាចផ្ដាច់ការរបស់គ្រួសារ និង សង្គមបានទេ ។

បុរសជាឪពុក រាល់ពេលសូត្រធម៌ថ្វាយបង្គំព្រះ តែងតែបួងសួង បន់ស្រន់សុំឲ្យបានកូនប្រុស ដើម្បីប្រគល់មរតក ជាបន្តជួយសម្រួលគ្រប់ការងារ ជួយធ្វើស្រែ និង មានសេចក្ដីក្លាហានទៅប្រយុទ្ធនៅលើសមរភូមិ ។ គ្មានកូនប្រុស ជាប្រភពមួយ ធ្វើឲ្យខ្មាសគេ និង អភ័ព្វ អពមង្គល នៅក្នុងគ្រួសារ ។ កំណើតកូនស្រីគេចាត់ទុកថា ជាប្រផ្នូលអាក្រក់ នៅក្នុងគ្រួសារ ។ កូនស្រីគ្មានសិទ្ធិទៅរៀន រស់តែក្នុងផ្ទះ ធ្វើការ និង បំរើគ្រួសារ ។ អាយុបាន ១៥ឆ្នាំ ត្រូវកាត់សក់ឲ្យខ្លី រហូតដល់អាយុ ២០ ឆ្នាំ ត្រូវរៀបការជាមួយបុរស ដែលឪពុករើសមកផ្សំផ្គុំ ដែលមានអ្នកមេអណ្ដើកជួយជ្រោមជ្រែង ចាត់ចែង ។ កូនស្រីគ្មានសិទ្ធិអ្វីនឹងប្រកែកបានទេ ទោះជារូបល្អ ឬ អាក្រក់ ស្រឡាញ់ ឬ មិនស្រឡាញ់ ត្រូវតែយល់ព្រមរៀបការ ជាដាច់ខាត ។

កូនស្រី ជាបន្ទុកធ្ងន់ណាស់ ចំពោះគ្រួសារ ក្រោយពីរៀប

អាពាហ៍ពិពាហ៍ រួចហើយ កូនស្រីត្រូវទៅបំរើស្វាមី និង គ្រួសាររបស់ប្តី ។ មួយជីវិតស្ត្រី ត្រូវរស់នៅក្រោមចំណុះអំណាច និងទទួលបញ្ជាពីស្វាមី ពីកូនប្រុស ។ ពេលបរិភោគអាហារ ស្ត្រីមិនអាចចូលរួមតុជាមួយបុរសទេ ត្រូវចាំនៅផ្ទះបាយ (បង្ក្រាន) ។ ភាសិតមួយបានចែងថា "បើភរិយានិយាយ ស្តាប់ទៅ តែកុំជឿ"។

ស្ត្រី គ្មានច្បាប់នឹងរៀបការជាថ្មីម្តងទៀតទេ ក្រោយពីស្វាមីរបស់ខ្លួន ទទួលមរណភាពទៅ ។ ស្ត្រី គ្មានសិទ្ធិនឹងទទួលមរតកសូម្បីតែប្រាក់ផ្ទាល់ខ្លួនក៏គ្មានដែរ លើកលែងតែសល់ពីចំណងដៃក្នុងពេលរៀបមង្គលការ ដែលគេសន្សំ ។

សម័យកាលពីឆ្នាំ ៩៥០ មានរាជាធិរាជ (empereur) ព្រះនាម លី យុ (LI YU) ទ្រង់បង្គាប់មហេសីព្រះអង្គម្នាក់ ក្នុងចំណោមមហេសីឯទៀតៗ ឲ្យរុំជើងនឹងក្រណាត់អំបោះពណ៌ស ឬពណ៌ខៀវ ដើម្បីឲ្យជើងតូចសម្រាប់រាំបង្វិលចុងជើង នៅលើជើងតម្កល់ ជារាងផ្កាឈូក ។

ព្រះអង្គ បញ្ជានាម៉ឺន ឲ្យទៅបង្គាប់ជាងពិសេស ឲ្យឆ្លាក់ជើងតម្កល់ជារាងផ្កាឈូក ធ្វើពីមាសបិទត្បូងពេជ្រជុំវិញ យកមកតាំងពាសពេញនៅក្នុងព្រះរាជវាំង ។

កាយវិការចុងជើងតូច លោតពីផ្កាឈូកមួយ ទៅផ្កាឈូកមួយ ហាក់ដូចជាខ្យល់កួចនាំយកទេពធីតា ឲ្យចុះមករាំបង្ហាញ ពី

សោភណភាពនៃជើងតូចនេះ ។ ដូច្នេះហើយ បានជាគេឲ្យឈ្មោះជើងតូចថា "ផ្កាឈូកមាស" ។

អ្នកនៅក្នុងវាំងខ្លះ ដែលមានកូនស្រី មានចិត្តសប្បាយរីករាយនឹងធ្វើតាមគំរូជើងតូចនេះ ដោយមិនបានយល់ពីវាសនា ដ៏សោកសង្រេង ប្រកបដោយទុក្ខភិតភ័យរបស់កូនស្រី ដែលប្រទះនឹងការឈឺចាប់ ហើយអាចក្លាយទៅជាពិការទៀតផង ។ ជាសំខាន់បំផុតទៅទៀតនោះ គឺការប៉ះទង្គិចទៅលើសតិអារម្មណ៍យ៉ាងខ្លាំងរបស់កូនស្រី ក្នុងពេលរុំជើងនេះ ។

តាមស្ថិតិ ស្ត្រីចំនួនរាប់លាន ដែលបានទទួលរងកម្មរបៀបនេះ មានរហូតដល់ ១០ % ស្លាប់ដោយរោគបង្ក មេរោគចូលក្នុងឈាម (Septicémi) [៤] ។ រូបថតនៅទំព័រ ១៦ ។

អ្នកករីចិនម្នាក់ឈ្មោះ លោក ទី មុយ បានសរសេរកំណាព្យកោតសរសើរ ស្ញើចពីគម្ពីរលំអនៃជើងតូចនេះ បានឮល្បីសុះសាយទូទាំងប្រទេសស្ទើរតែគ្រប់ភូមិភាគ នៃប្រទេសចិន លើកលែងតែប្រជាជនចិន ប៉ែកខាងឦសាន (La Manchourie) គេមិនប្រព្រឹត្តអំពើរុំជើងនេះ ។

ស្ត្រីជាម្ដាយ យល់ឃើញថា ដើម្បីនឹងឲ្យអានាគតដ៏ល្អ

---

[៤] -Wikipédia

ប្រៀងរបស់កូនស្រី ត្រូវតែអនុវត្តគំរោងការរុំជើងឲ្យតូច ចាប់តាំងពីអាយុ ៤ ឆ្នាំឡើងទៅ ។ កូនស្រីខ្លះ ត្រូវម្ដាយបង្ខំរុំជើងមុនអាយុ ៤ឆ្នាំទៅទៀត ដើម្បីឲ្យមានទំហំត្រឹមតែ ៧ សង់ទីម៉ែត្រ ទទឹង និង ១៥សង់ទីម៉ែត្របណ្ដោយ នៅពេលដល់អាយុ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ ។ ព្រោះម្ដាយសង្ឃឹមថា នេះជានិមិត្តរូបនៃកិត្តិនាម និង សេចក្ដីថ្លៃថ្នូររបស់គ្រួសារអ្នកមានស្ដុកស្ដម្ភ ដែលគេត្រូវតែគោរពកោតសរសើរ ។

ពេលគេចូលមកស្ដីដណ្ដឹងកូនក្រមុំ គេសុំមើលតែរង្វង់ស្បែកជើងកូនក្រមុំទេ ។ កូនស្រីណាមានស្បែកជើងប្រវែង១៥សង់ទីម៉ែត្រ កូនស្រីនោះនឹងមានភ័ព្វវាសនាខ្ពង់ខ្ពស់ សម្បូណ៌សប្បាយ ព្រោះគ្រួសារសេដ្ឋី ឬ គ្រួសារអ្នកមានអំណាច គេខិតខំស្រាវជ្រាវដើររកយកមកធ្វើជាកូនប្រសា ព្រោះជាកិត្តិយស និង ធ្វើឲ្យគេគត់សំគាល់បានថា ជាគ្រួសារមួយមានភាពខ្ពង់ខ្ពស់ អង់អាចថ្លៃថ្នូរ ខុសប្លែកពីគ្រួសារឯទៀតៗ ។

ពេលនោះ ស្រីប្រមូលនាំគ្នារៀបចំគូរជារូបផ្កា ឬ ក្បាច់ណាៗ ។ យកមកចង្អូលផ្ចិតនៅលើក្រណាត់ស្បែកជើង រួចដេរដាក់ដោយប្រុងប្រយ័ត្នព្យាយាមមិនចង់ឲ្យល្អិតជាទីបំផុត ។

ដើម្បីជាភស្ដុតាងនូវសោភ័ណភាពនៃលំអជើងតូច ស្រី ក៏ចាប់ផ្ដើមមានមុខការងារផ្ទាល់រៀងៗខ្លួន ។

នៅប្រទេសអ៊ឺរ៉ុប គេយល់ថា ការរុំជើងនេះ ជាអំពើឃោរឃៅ ។ រដ្ឋអំណាចនៅប្រទេសរុស្ស៊ី បានហាមឃាត់លោក ឯកអគ្គរាជទូតចិន ប្រចាំនៅប្រទេសរុស្ស៊ី មិនឲ្យយកស្រីណាដែលមានជើងតូច ចូលមកប្រទេសរុស្ស៊ីទេ ។

ប្រពៃណីរុំជើងប្រចាំត្រកូល បានបាត់ទៅបន្តិចម្តង ។ ក្នុងពេលដែលប្រទេសចិនប្តូរ ទៅជាប្រទេសសាធារណរដ្ឋជាតិនិយមក្នុងឆ្នាំ ១៩១២ ។ ចាប់តាំងពីពេលនោះមក រដ្ឋាភិបាលបង្កើតច្បាប់ហាមមិនឲ្យរុំជើងទៀត ហើយនឹងបញ្ជាឲ្យស្រាយក្រណាត់រុំជើងចោលចេញឲ្យអស់ ។

ចាប់ពីឆ្នាំ ១៩៤៩ សាធារណរដ្ឋប្រជាមានិតចិន បញ្ជាក់ឲ្យគោរពច្បាប់ឈប់ឲ្យរុំជើងទៀត ។

ឆ្នាំ ១៩៥០ ចេញច្បាប់ មិនឲ្យមានការបង្ខិតបង្ខំក្នុងការរើសគូរដណ្តឹង ។

ឆ្នាំ ១៩៥៣ ស្ត្រីមានសិទ្ធិចូលទៅបោះឆ្នោត ។

ឆ្នាំ ១៩៥៨ ស្ត្រីមានសិទ្ធិទៅរៀនសូត្រ អប់រំរហូតមកដល់សព្វថ្ងៃ ស្ត្រីខ្លះបំពេញមុខងារជាតំណាងរាស្ត្រ ស្ត្រីខ្លះបានទទួលរង្វាន់មេដាយមាសក្នុងការប្រកួតកីឡាអូឡាំពិកក្នុងឆ្នាំ ២០០៨ ស្រីម្នាក់ទៀតកំពុងតែរៀបចំខ្លួនឡើងទៅលើលោកខែ ក្នុងឆ្នាំ ២០១២ខាងមុខនេះ ។

ស្រីដំបូងបង្អស់ ដែលបាន ទៅដល់លោកខែមុនគេ នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៦៣ ជាជនជាតិសូវៀត ឈ្មោះ វ៉ាឡង់ទីណា វ្លាឌីមីរ៉ូវណា តេរេស្កូវ៉ា (Valentina Vladimirovna Terechkova)



ប្រទេសអ៊ឺរ៉ុប ប្រទេសអាមេរិក ប្រទេសចិន ប្រទេសជប៉ុន ធ្លាប់បានបញ្ជូនស្ត្រីទៅលោកខែជាបន្តបន្ទាប់ ។













# សិទ្ធិស្ត្រី នៅប្រទេសជប៉ុន [៥]

ស្ត្រីជប៉ុន មានសេរីភាព មានការអប់រំល្អប្រពៃ មានចំណេះចេះដឹងជ្រៅជ្រះ ជាអ្នកកវី ជាអ្នកនិពន្ធ តាំងពីឆ្នាំ ៨០០-១០០០ មក ។

នៅក្នុងសង្គមប្រទេសជប៉ុន គេសន្មតថា គ្មានភាពសមរម្យចំពោះកូនស្រីអាយុ ២៥ ឆ្នាំ ដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍។ ៩៥% កូនស្រីយល់ព្រមរៀបមង្គលការនេះ ព្រោះចង់បានសន្តិសុខលើសលប់ជាងសេចក្តីស្រឡាញ់ ។

ពិធីមង្គលការ មានរយៈពេលតែ ៣ ម៉ោង នៅឯសណ្ឋាគារ តែត្រូវចំណាយអស់រាប់លានយេន ។ ភ្ញៀវជាកិត្តិយស ចូលចំណងដៃជាប្រាក់ដាក់ក្នុងស្រោមសំបុត្រ កូនក្រមុំ-កម្លោះ ជូនវត្ថុអនុស្សាវរីយ៍ និង ថ្លែងអំណរគុណនូវពេលភ្ញៀវត្រឡប់ទៅវិញ ។

ពេលរៀបការហើយ ប្រពន្ធរស់នៅជាមួយឪពុក-ម្ដាយផ្ទាល់ខ្លួន ស្វាមីមានច្បាប់មករកប្រពន្ធ តែពេលយប់ទេ ។

មកដល់សតវត្សរ៍ទី ១៤ ទើបប្ដី-ប្រពន្ធ និង កូនរស់នៅបែកចេញពីគ្រួសារ ។

គ្រប់គ្រួសារព្រាថ្នាចង់បានតែកូនប្រុសទេ ។ កូនទាំងអស់

---

[៥] -www.alyon.org/... japon/.../condition_femme.html

កើតឡើងត្រូវយកនាមត្រកូលខាងម្ដាយ ។

ពេលណាដែលគេនិយាយពីប្រទេសជប៉ុន គឺគេចង់និយាយពីសង្គមអត់ឪពុក ។ បុរសធ្វើការច្រើនណាស់ ដើម្បីចិញ្ចឹមគ្រួសារ។ តែក្រៅពីម៉ោងធ្វើការ គេនិយមទៅចូលរួមប្រជុំជាមួយសហការី ឬជួបជុំមិត្រជាច្រើននៅតាមភោជនីយដ្ឋាន និង ហាងកាហ្វេ គេចូលចិត្តសប្បាយនៅក្រៅផ្ទះណាស់ ។

ស្ត្រីខ្លះធ្វើការស្មើនឹងបុរស ការងារធ្វើដូចគ្នា តែបុរសបានទទួលប្រាក់ខែលើស ៥៧% ។

ជាពិសេសទៅទៀតនោះ ស្ត្រីខ្លះ រងគ្រោះដោយត្រូវគេប្រមាថនៅក្នុងកន្លែងធ្វើការ គេក៏មិនរវល់អើពើ ឬក៏ បារម្ភអ្វីបន្តិចដែរ ។ ស្ត្រីមានច្បាប់សុំឈប់សម្រាកមុន និង ក្រោយឆ្លងទន្លេ តែជួនកាលអ្នកថៅកែ ឬ អ្នកនាយក បង្ខំឲ្យដាក់ពាក្យសុំលាលែងពីកន្លែងឈប់ធ្វើការតែម្ដង ។

ស្ត្រីខ្លះ គ្មានលទ្ធភាពបញ្ជូនកូនទៅកន្លែងទារកដ្ឋានទេ ត្រូវបង់ប្រាក់ធ្ងន់ពេក ឬ ក៏ម៉ោងមិនស្របនឹងកន្លែងធ្វើការ ។

ស្ត្រីត្រូវងើបមុនគេបង្អស់ រៀបចំធ្វើម្ហូបអាហារ រៀបចំបោសជូត សំអាតផ្ទះ អប់រំប្រៀនប្រដៅកូន ពិនិត្យតាមដំណើរការរៀនសូត្ររបស់កូន រហូតដល់ចប់ ។ គេសន្មតសមត្ថភាពចំណេះដឹងរបស់ម្ដាយ ដោយផ្អែកទៅលើលទ្ធផលរបស់កូន ។

គេឃើញអគ្រាសំខាន់ដែលម្ដាយខ្វះសម្ងាប់ខ្លួន ព្រោះតែចិញ្ចឹមប្រៀនប្រដៅកូនមិនបានសមរម្យល្អ នាំឲ្យខ្មាសគេ ។

មកដល់ឆ្នាំ ១៦០០ សិទ្ធិរបស់ស្ត្រី រលាយសាបសូន្យអស់ដោយសារតែយោធា និង សាមូរ៉ៃ ដែលជាអ្នកកាន់អំណាច ។ ជីវិតស្លាប់ ឬ រស់របស់ស្ត្រី ស្ថិតនៅក្រោមការសម្រេចរបស់បុរស ។ បុរសអាចមានប្រពន្ធច្រើន ហើយមានសិទ្ធិយកមករស់នៅក្រោមដំបូលផ្ទះ ជាមួយប្រពន្ធដើមទៀតផង ។

មកដល់ឆ្នាំ ១៨៦៨ អំណាចនៃរាជាធិរាជ មានចិត្តទូលំទូលាយណាស់ បញ្ចេញ បង្ហាញប្រទេសជប៉ុន និង មានការទំនាក់ទំនងជាមួយនឹងប្រទេសឯទៀត ៗ ក្នុងពិភពលោក ។

ស្ត្រីចាប់ផ្ដើមធ្វើចលនាទាមទារច្បាប់ ស្ដីពីការសិក្សាចំណេះវិជ្ជាឲ្យបានខ្ពស់ ។ កូនស្រីជំនាន់នោះ ទទួលការណែនាំបង្ហាត់បង្រៀន អប់រំដ៏ខ្ពង់ខ្ពស់ពីម្ដាយ ដើម្បីឲ្យក្លាយទៅជាភរិយាដ៏ល្អប្រសើរ ប្រកបដោយសេចក្ដីថ្លៃថ្នូរ មានចរិយាទន់ភ្លន់ ចេះគោរពគួរសមចំពោះស្វាមី ព្រមទាំងញាតិជិតឆ្ងាយផងដែរ ។

មកដល់ឆ្នាំ ១៨៨០ ស្ត្រីមានការហាមឃាត់ និង គ្មានសេរីភាព ខាងផ្លូវនយោបាយទេ ឯបុរស ក៏នៅតែមានប្រពន្ធច្រើន ។ ស្ត្រីមេម៉ាយ គ្មានច្បាប់នឹងចាកចេញពីផ្ទះ ដោយគ្មានការអនុញ្ញាតពីគ្រួសារប្ដីទេ ។

# សិទ្ធិ ស្ត្រី នៅប្រទេសបារាំង[៦]

គេទុកស្ត្រីជាប្រពន្ធ ស្ត្រីជាម្ដាយ ស្ត្រីជាអ្នកមេផ្ទះ រហូតដល់មានអ្នកកវីនិពន្ធដ៏ល្បីម្នាក់ឈ្មោះ លោក Molière តែងរឿង "សាលាស្ត្រី" ហើយឲ្យសំដែងជាឆាកល្ខោនក្នុងឆ្នាំ ១៦៦២ ដើម្បីកោតសរសើរពីគុណសម្បត្តិរបស់ស្ត្រី ដែលទុកស្វាមី ជាអាទិទេព ជាអ្នកដឹកនាំ ជាម្ចាស់ មានន័យថា ស្ត្រីកើតមកសម្រាប់បំរើប្រយោជន៍បុរស តែប៉ុណ្ណោះ ។

ស្ត្រីបារាំងស្រឡាញ់ ចូលចិត្តស្ដាប់ រែករៀក ពិភាក្សាពីនយោបាយណាស់ ។ ស្ត្រីភាគច្រើន គ្មានពាក្យផ្អែមល្ហែមលួងលោមស្វាមីទេ ប្រសិនណាបើស្វាមី មិនបានរៀបរាប់ពីនយោបាយ ។

រហូតមកដល់ឆ្នាំ ១៧៨៩ ប្រជារាស្ត្របារាំង ទាំងប្រុស ទាំងស្រី គ្មានច្បាប់ទៅបោះឆ្នោតទេ ព្រោះព្រះអង្គ ល្វី សី (Louis XVI) ទ្រង់កាន់អំណាចប្រកបទៅតាមឋានានុក្រម ឬ ទៅតាមលំដាប់ស័ក្តិ ។

---

[៦] -(Les françaises face à la politique) comportement politique et condition sociale par Mattei DOGAN et jacque NARBONNE, Cahiers de la fondation nationale des sciences politique , n°72, Librairie Armande Colin, Paris 1955.

រាល់ពេលប្រជុំនៅរដ្ឋសភា គេមិនដែលលើកយកសិទ្ធិស្ត្រី មកធ្វើអត្ថាធិប្បាយទេ ។

ក្នុងខែតុលា ឆ្នាំ ១៧៨៩ នេះ ការធ្វើបដិវត្តន៍ ក៏ចាប់ផ្តើមឡើង ស្ត្រីជាច្រើន បានចូលរួមគ្នាបង្កើតជាក្រុម ហើយក្រុមនីមួយ ៗ មានឈ្មោះថា "ស្ត្រីជាពលរដ្ឋបដិវត្ត ពេញលក្ខណៈ-សង្គមស្ត្រីស្នេហាមាតុភូមិ ស្ត្រីស្មោះត្រង់ចំពោះមិត្ត ស្រឡាញ់សេរីភាព" ។

ទុកជាគេមិនឲ្យសិទ្ធិ ឬ មិនការពារសិទ្ធិ ក៏ ស្ត្រីនៅតែយល់ថា "បើចង់បានសិទ្ធិ យើងត្រូវតែបង្ហាញករណីយកិច្ចរបស់យើង គឺជាភស្តុតាងនូវភក្តីភាព នូវសេចក្តីស្មោះត្រង់ ទុកចិត្ត មានសច្ចៈយុត្តិធម៌ យើងមិនចាំបាច់ជជែករកខុសត្រូវទេ យើងត្រូវបន្តដំណើរ សកម្មភាព បង្កើនករណីយកិច្ច ជាញឹកញាប់ ប្រកបដោយចរិតត្រឹមត្រូវល្អ ដើម្បីឲ្យគេយល់ព្រមឲ្យសិទ្ធិមកយើង"[៧] ។

លោកស្រីម៉ារី អូឡាំព ដឺគូស Marie - Olympe de Gouges ជាមួយនឹងសហការីម្នាក់ឈ្មោះ តេរ៉ូញ ដឺមីរីគួរ Théroigne de Méricourt បានតែងអត្ថបទទៅថ្វាយព្រះមហាក្សត្រិយានី ម៉ារី

---

[៧]-Les femmes et leur histoire par Geneviève Fraisse, Gallimard 1998, page 339.

រាល់ពេលប្រជុំនៅរដ្ឋសភា គេមិនដែលលើកយកសិទ្ធិស្ត្រីមកធ្វើអត្ថាធិប្បាយទេ ។

ក្នុងខែតុលា ឆ្នាំ ១៧៨៩ នេះ ការធ្វើបដិវត្តន៍ ក៏ចាប់ផ្ដើមឡើង ស្ត្រីជាច្រើន បានចូលរួមគ្នាបង្កើតជាក្រុម ហើយក្រុមនីមួយ ៗ មានឈ្មោះថា "ស្ត្រីជាពលរដ្ឋបដិវត្ត ពេញលក្ខណៈ-សង្គមស្ត្រីស្នេហាមាតុភូមិ ស្ត្រីស្មោះត្រង់ចំពោះមិត្ត ស្រឡាញ់សេរីភាព" ។

ទុកជាគេមិនឲ្យសិទ្ធិ ឬ មិនការពារសិទ្ធិ ក៏ ស្ត្រីនៅតែយល់ថា "បើចង់បានសិទ្ធិ យើងត្រូវតែបង្ហាញករណីយកិច្ចរបស់យើង គឺជាភស្តុតាងនូវភក្ដីភាព នូវសេចក្ដីស្មោះត្រង់ ទុកចិត្ត មានសច្ចៈយុត្តិធម៌ យើងមិនចាំបាច់ជជែករកខុសត្រូវទេ យើងត្រូវបន្តដំណើរ សកម្មភាព បង្កើនករណីយកិច្ច ជាញឹកញាប់ ប្រកបដោយចរិតត្រឹមត្រូវល្អ ដើម្បីឲ្យគេយល់ព្រមឲ្យសិទ្ធិមកយើង"[៧] ។

លោកស្រីម៉ារី អូឡាំព ដឺគូស Marie - Olympe de Gouges ជាមួយនឹងសហការីម្នាក់ឈ្មោះ តេរ៉ូញ ដឺមេរីគួរ Théroigne de Méricourt បានតែងអត្ថបទទៅថ្វាយព្រះមហាក្សត្រិយានី ម៉ារី

[៧]-Les femmes et leur histoire par Geneviève Fraisse, Gallimard 1998, page 339.

អង់តែណិត Marie Antoinette ជាព្រះអគ្គមហេសីស្ដេច ល្វី សី Louis XVI សុំឲ្យស្ត្រីនិងបុរស មានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ មានកិត្តិយសដូចគ្នា និងសុំចូលទៅធ្វើការរដ្ឋគ្រប់វិស័យ ដូចបុរសដែរ ។

បន្តិចក្រោយមក អ្នកបដិវត្តដូចគ្នា ដែលមានគំនិត មិនស្របតាម លោកស្រី ម៉ារី អូឡាំព ដឺគួស Marie-Olympe de Gouges ដោយសារលោកស្រីធ្វើសេចក្ដីប្រកាស សុំឲ្យលប់បំបាត់ចោលនូវ : ១-ការប្រឆាំងជាមួយនឹងទាសៈ ២-កុំយកអ្នកទោសទៅសម្លាប់ ៣-ឲ្យមានការស្អិទស្អាល ជៀសវាងអំពើឃោរឃៅគម្រាមធ្វើទុក្ខទោស ៤-ការពារក្មេងកំព្រា និង ស្ត្រីមានកូនតែគ្មានប្ដី ។

អ្នកបដិវត្តដូចគ្នានេះ បានយកលោកស្រី ទុកនៅក្នុងពន្ធនាគារបាស្ទី «Bastille» បន្ទាប់មកត្រូវអ្នកបដិវត្ត យកទៅកាត់ក្បាល ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ១៧៩៣ ក្នុងអាយុ ៤៥ ឆ្នាំ ។

ថ្ងៃទី ៣ ខែឧសភា ឆ្នាំ ១៧៩៣ គេឲ្យលោកស្រីតេរ៉ូញ ដឺ មេរីគួរ Théroigne de Méricourt នៅខ្លួនទទេ បណ្ដើរទៅមុខប្រជាជន វាយនឹងរំពាត់ខ្សែតី ។ ឆ្នាំ ១៧៩៥ នៅមន្ទីរពេទ្យវិកលចរិត លោកស្រី បានទទួលមរណភាព នៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៨១៧ នៅមន្ទីរពេទ្យសាល់ ប៉េត្រីយែរ «Hôpital

de la Salpêtrière de Paris» ។

ក្រមរដ្ឋប្បវេណី code civil របស់ណាប៉ូឡេអុង ទី ១ NAPOLEON 1er ក្នុងឆ្នាំ ១៨០៧ ក៏បានបញ្ជាក់ច្បាស់ទៀត ស្តីពីភាពមិនស្មើគ្នារវាងបុរស និង ស្ត្រី ។

ពីឆ្នាំ ១៨៧០ ទៅ ១៩៣៩ សមាគមស្ត្រីជាច្រើន រួបរួមបង្កើតបក្ស-សម្ព័ន្ធ សុំឲ្យរដ្ឋាភិបាល បង្កើតច្បាប់ទទួលស្គាល់សិទ្ធិស្ត្រី ។

ក្នុងឆ្នាំ ១៩៤៦ បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នាចូលទៅបោះឆ្នោតស្របតាមរដ្ឋធម្មនុញ្ញ ។

ស្ត្រីជាច្រើន បានបង្ហាញសមត្ថភាពពីការចេះដឹង ដែលជាកិត្តិយស ជាតម្លៃ ជាប្រយោជន៍ និង ការលូតលាស់ជឿនលឿនរបស់ស្ត្រី ចំពោះប្រទេសជាតិ ។

ឆ្នាំ ១៨៥១ លោកស្រី ម៉ារីអង់ សេលីគ ឌុយសឺម៉ាំង Marie-angélique Duchemin បានទទួលរង្វាន់ គ្រឿងឥស្សរិយយស "យុទ្ធជន សាធារណរដ្ឋ" ។

ឆ្នាំ ១៨៧៥ លោកស្រី ម៉ាឌឺលែន ប្រេស Madeleine Brès រៀនជាប់វេជ្ជបណ្ឌិត ។

ឆ្នាំ ១៩០៣ លោកស្រី ម៉ារី គូរី Marie Curie បានទទួលរង្វាន់ Prix Nobel ខាងរូបសាស្ត្រពិសោធ និង ខាងគីមី "វិទ្យា-

សាស្ត្រខាងផ្សំធាតុ" ក្នុងឆ្នាំ ១៩១១ ។

ឆ្នាំ ១៩១០ លោកស្រី អេលិស ដឺរូស Elise Deroche ជាប់ប្រកាសនីយប័ត្របើកបរយន្តហោះ ។

ក្នុងប្រទេសបារាំងសព្វថ្ងៃនេះ យើងឃើញស្ត្រីភាគច្រើនមានសញ្ញាប័ត្រជាន់ខ្ពស់ស្មើនឹងបុរស ចូលរួមនយោបាយ យ៉ាងសកម្មក្នុងរដ្ឋាភិបាលគ្រប់វិស័យ ឬ ជាឯកជន និង សាធារណៈ ។

ក្នុងនាមជាស្ត្រី ទុកជាមានឋានន្តរស័ក្តិខ្ពង់ខ្ពស់ប៉ុណ្ណា ក៏ដោយ ក៏នៅតែមិនភ្លេចករណីយកិច្ច ជាម្តាយ ជាប្រពន្ធ ជាជីដូនដើម្បីរក្សាសុភមង្គល និង សេចក្តីសុខនៅក្នុងគ្រួសារ ។ បានសេចក្តីថា បើមានសេចក្តីសុខនៅក្នុងគ្រួសារ យើងក៏មានសេចក្តីសុខនៅក្នុងសង្គមដែរ ដើម្បីរួបរួមកសាងប្រទេសជាតិ ឲ្យបានរីកចំរើនរុងរឿង ថ្កុំថ្កើង តទៅអនាគត សម្រាប់កូនចៅជំនាន់ក្រោយទៀត ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ចំពោះព្រះអង្គគ្រូ ឃិន ភេន ដែលព្រះអង្គបានណែនាំឲ្យធ្វើសិក្ខាសាលាស្តីពី សិទ្ធិស្ត្រី ។

សិក្ខាសាលានេះ មានសារសំខាន់ណាស់ ធ្វើឲ្យខ្ញុំព្រះករុណាខ្ញុំ បានយល់ច្បាស់ពីច្បាប់ និង ប្រពៃណី ។ ជាពិសេស ស្ត្រីខ្មែររស់នៅក្នុងប្រទេស ទទួលនូវការគាបសង្កត់ដ៏ធ្ងន់ធ្ងរ ពីរដ្ឋអំណាច

ដែលគេយកច្បាប់ និង ប្រពៃណី មកលាយឡំមិនច្បាស់លាស់ ធ្វើឲ្យស្ត្រីខ្មែរជួបប្រទះនឹងការរងទុក្ខវេទនាខ្លោចផ្សា បាត់កិត្តិយសក្នុងភេទជាស្ត្រីខ្មែរ ។

ខ្ញុំព្រះករុណាខ្ញុំ សូមអរព្រះគុណ សូមអរគុណ ៕



ម៉ារី អូឡាំភ ដឺគូ
Marie-Olympe d Gouges



ពន្ធនាគារ បាស្ទីយ ឆ្នាំ ១៧៨៩



តេរ៉ោញ ដឺ មេរ៉ីគួរ
Théroigne de Méricour



៩៩ឆ្នាំក្រោយមក
ឆ្នាំ ១៨៨៨
99ans plus tard,
Batslle en 1988

Photo par google

# សិទ្ធិស្ត្រីខ្មែរ ក្នុងអតីតកាល និង ក្នុងបច្ចុប្បន្ន

ដោយលោកស្រី អ៊ុង មឹង ឡាមីញែល

៙❁៚

ពាក្យថា "ស្ត្រីខ្មែរ" ធ្វើឲ្យខ្ញុំស្រមៃឃើញមនុស្សស្រីដែលមានរូបសមរម្យ មានសម្ផស្សគួរឲ្យស្រឡាញ់ មិនឆើតឆាយ ទឹកមុខញញឹម មានអំណត់ ចាំស្តាប់សំដីអ្នកនៅជុំវិញខ្លួន មានពាក្យទន់ភ្លន់ ផ្អែមល្ហែម ។ គឺជាភរិយាប្រសើរ ជាមាតាគួរឲ្យគោរព ជាមេផ្ទះដឹកនាំគ្រួសារ ឲ្យស្គាល់សុខដុមរមនា ។

តើស្ត្រីនោះ មានជីវិតប្រែប្រួលយ៉ាងណា ពីសតវត្សមួយទៅសតវត្សមួយ ? ខ្ញុំសុំចែកកំណត់ពេលទាំងនោះ ជា ៣ វគ្គគឺ :

១-ពីដើមកំណើត មកទល់សតវត្សទី ១៤ ។

២-ពីសតវត្សទី ១៤ មកទល់នឹងសតវត្សទី ២០ ។

៣-ពីឆ្នាំ ១៩២០ មកដល់ជំនាន់នេះ ។

## ១-ពីដើមកំណើត មកទល់សតវត្សទី ១៤

នៅសម័យនោះ ក្មេងភេទស្រីមានសិទ្ធិដណ្តឹងភេទប្រុសមកធ្វើជាគ្រួសារ ។ លុះបានគ្រួសារហើយ ខ្លួនឯងជាមេគ្រួសារ មានសេរីភាពគ្រប់គ្រាន់ ដូចជា :

ក-ចំណាយសម្បត្តិគ្រួសារ ធ្វើជាអំណោយជាមួយប្តី ឬ តែម្នាក់ឯង ។

ខ-ជាបង្គោលក្នុងគ្រួសារ ។

គ-ជាអ្នកឲ្យយោបល់ប្តី ។

ឃ-ការតស្វវង្សត្រកូល គឺត្រូវគិតតាមខ្សែប្រពន្ធ ។ គេហៅមនុស្សប្រុសតាមឈ្មោះផ្ទាល់ខ្លួន តែបើមានប្រុស ២ នាក់ឈ្មោះដូចគ្នា គេយកឈ្មោះប្រពន្ធ មកភ្ជាប់បន្ថែមរៀងខ្លួន ។

ង-ប្រុសត្រូវនៅបម្រើឪពុក ម្តាយ ក្មេក មុននឹងសម្រេចឲ្យកូនស្រី ។ ដូច្នេះ នៅក្នុងច្បាប់ខ្មែរជំនាន់ដើម ស្ត្រីមានភាពខ្ពស់ជាងបុរស ។ គុណសម្បត្តិមួយទៀត គឺស្ត្រី មានប្រាជ្ញាឆ្លាតវៃពូកែខាងធ្វើជំនួញ ។ ចំណែកខាងការថែរក្សារូបសម្បត្តិគេវិញ គឺគេលាបសាច់គេឲ្យមានសម្បុរ ស ដូចទឹកដោះគោ ហើយមានសិទ្ធិលាបថ្នាំលើបាតដៃ បាតជើង... រីឯបុរសវិញ មិនមានធ្វើទេ ។

## ២-ពីសតវត្សទី ១៤ មកទល់នឹងសតវត្សទី ២០

ចាប់ពីសតវត្សទី ១៤ មក ការគួរឲ្យសោកស្តាយ គឺឋានៈស្ត្រីខ្មែរ បានចុះទាបយ៉ាងខ្លាំងជាលំដាប់ ។ ក្នុងរយៈពេល ៣០០ ឆ្នាំនោះ យើងគ្មានកំណត់ហេតុអ្វី ស្តីពីលក្ខន្តិកៈស្ត្រីឡើយ ។ ខ្ញុំសូមជំរាបថា ក្រមច្បាប់ខ្មែរ ចាស់ជាងគេ នៅមានក្នុងសតវត្សទី ១៣ ។ តាមកំណត់របស់អ្នកដំណើរ ចិន ឈ្មោះ ចូវ តា ក្វាន់ ពីឆ្នាំ ១២៩៦ គាត់បានសរសេរជាច្រើនអំពីលក្ខណ្ឌជីវភាពនៃស្ត្រីខ្មែរនាពេលនោះ ជាពិសេស អំពីចំណោះវិជ្ជាខ្ពង់ខ្ពស់ អំពីការពូកែធ្វើ

ជំនួញ និង សិទ្ធិផ្សេង ។ របស់ស្ត្រីខ្មែរ ព្រមទាំងសរសើរអំពីរូបសម្បត្តិរបស់គេផង ។ លោក ចូវ តា ក្វាន់ បានសរសើរពីការល្អតលាស់ ការរីកចំរើននៃប្រទេសខ្មែរ និងភាពរុងរឿងខ្ពស់ត្រដែតនៃប្រាសាទនានា នៅក្រុងអង្គរដ៏ធំសម្បើម គ្មានអ្វីផ្ទឹមបាន ។ ទាំងអស់នេះ ធ្វើឲ្យយើងដឹងថា ប្រទេសខ្មែរ ជាប្រទេសមានអំណាចណាស់ ។ គេអាចស្មានបានថា បុព្វហេតុដែលនាំឲ្យឋានៈស្ត្រីចុះដុនដាបយ៉ាងនេះ គឺ ដោយសារតែចម្បាំងឥតឈប់ឈរ ធ្វើឲ្យប្រទេសទន់ខ្សោយ បាត់ឈ្មោះ សាបសូន្យ ។ លុះចូលមកសតវត្សទី ១៩ ទើបប្រទេសខ្មែរ បានលេចឮឈ្មោះឡើងវិញដោយសារប្រាសាទអង្គរ ។

អ្វីដែលជាភ័ស្តុតាងបង្ហាញឲ្យឃើញថា ភាពស្ត្រី ប្រែប្រួលគឺ :

ក-ក្មេងស្រីត្រូវនៅក្រោមអាណាព្យាបាលឪពុក រហូតដល់ពេលរៀបការហើយ បាត់សិទ្ធិរើសប្ដីខ្លួនឯងទៀតហើយ ។

ខ-ប្ដីអាចមានប្រពន្ធច្រើនទៀត ។

គ-ស្ត្រី ឥតមានសិទ្ធិធ្វើអ្វី ។ សព្វសារពើ ដូចជាធ្វើជំនួញបានតាមចិត្ត បើចង់ធ្វើ ត្រូវសុំសេចក្ដីអនុញ្ញាតពីប្ដី ។

ឃ-ត្រូវនៅផ្ទះជាមួយប្ដី (Le domaine conjugal est la Maison du mari) កាលណាប្រពន្ធចុះចោលផ្ទះ ចំនួន ១ យប់ ដោយ

គ្មានបុព្វហេតុសមរម្យ ប្តីអាចប្តឹងសុំលែងបាន ។ ចំណែកប្តីវិញ ទោះជាទៅចោលផ្ទះ ៣ ខែ ដោយគ្មានបុព្វហេតុសមរម្យ ហើយមិនបានផ្តល់ប្រាក់កាស សំរាប់ឲ្យប្រពន្ធ កូនរស់ អត់បានជាបុព្វ-ហេតុ សុំលែងលះប្តីប្រពន្ធបានទេ ។ ប្តីមានសិទ្ធិ យកប្រពន្ធទៅលក់ តែត្រូវមានការយល់ព្រម ពីប្រពន្ធជាមុនសិនដែរ ។ ច្បាប់ចែង ទៀតថា :

ង-បើប្តីត្រូវការប្រាក់កាស អាចយកប្រពន្ធ កូន ចៅ ទៅបញ្ចាំក្នុងរយៈកាលតែ ១ ឆ្នាំទេ ។ រួចពី ១ ឆ្នាំនោះ ប្រពន្ធ កូន ចៅ អាចចេញរួចខ្លួន ។

ច-ប្តី ជាចៅហ្វាយត្រួតត្រាលើប្រពន្ធគ្រប់បែបយ៉ាង ។

ឆ-ប្តីមានសិទ្ធិសម្លាប់ប្រពន្ធផិតក្បត់ ។

ជ-ប្តីត្រួតត្រាលើសម្បត្តិទ្រព្យប្រពន្ធ ។

ឈ-ស្ត្រីក្លាយខ្លួនជាទាសីរបស់ប្តី ។

-បើប្តីស្លាប់ ទ្រព្យដើមរបស់ប្រពន្ធ ប្រពន្ធយកវិញបាន។ ចំណែកឯទ្រព្យរួម ប្រពន្ធទទួលបាន ១ ភាគ ៣ "ប្តី វែក ប្រពន្ធ ទូល" ។ រីឯកូនប្រុស ស្រី គេទទួល កេរមរតក ស្មើគ្នា ។

ទោះបីក្នុងក្រមរដ្ឋប្បវេណី (Code civil Cambodien) ថា: ប្រពន្ធ ត្រូវផ្ទាក់ទាប ហើយកូន ៗ ត្រូវនៅក្នុងអាណាព្យាបាល របស់ឪពុក តែនៅក្នុងជីវភាពជាក់ស្តែង គេមិនឃើញឪពុក វាយ

ធ្វើជាបក្ខន ។ ឡើយ ។ ចំណែកឯប្រពន្ធ ត្បិតប្តីបានឡើងជាចៅហ្វាយ អាចមានប្រពន្ធច្រើន ក៏គេសំគាល់ឃើញថា ប្តីមានប្រពន្ធតែមួយទេ ហើយប្រពន្ធនោះ ក៏នៅជាអ្នកកាន់កាប់ប្រាក់គ្រួសារ ។ យើងធ្លាប់ឮគ្រួសារខ្មែរ នៅស្រុកស្រែ ប្តី ហៅប្រពន្ធថា "ផ្ទះខ្ញុំ" ឬថា "គេហ៍" មានន័យថា "ផ្ទះ" ។

**៣-ពីឆ្នាំ ១៩២០ មកដល់ពេលនេះ**

ខ្ញុំសូមជំរាបថា ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ប្រទេសខ្មែរនៅក្នុងការគ្រប់គ្រងខ្មែរក្រហម ដែលច្បាប់ផ្សេង ៗ ត្រូវចេញមកពី "អង្គការលើ" ដោយមាត់ទទេ ។

ច្បាប់ក្រមថ្មីរបស់ខ្មែរ បានកើតមាននៅឆ្នាំ ១៩២០ ដែលជាឆ្នាំផ្សាយ "ក្រមរដ្ឋប្បវេណី" (Code civil Cambodien) ដែលបារាំងណែនាំឲ្យរៀបចំ ។ ក្នុងក្រមរដ្ឋប្បវេណីនេះ នៅត្រង់ចំណុចសិទ្ធិស្ត្រីខ្មែរ គេបានចំឡងចេញខ្លះ ពីច្បាប់ចែងលើស្ត្រីបារាំង គឺថា ប្តី ជាមេគ្រួសារ មានសិទ្ធិលើប្រពន្ធ ដោយគេចាត់ទុកស្ត្រីជាបុគ្គលទន់ខ្សោយ ទទួលខុសត្រូវដោយខ្លួនឯងមិនបាន ។ ចំណែកឯ ច្បាប់ប្រុសអាចមានប្រពន្ធច្រើន នៅទុកប្រើតទៅទៀត ។ តើអ្នកតែងច្បាប់ដែលជាជាតិបារាំងនោះ ហេតុអ្វីបានជាធ្វើក្រមរដ្ឋប្បវេណីខ្មែរ ដោយមិនពិនិត្យឲ្យហ្មត់ចត់ យកច្បាប់បុរាណខ្មែរ ដែលស្ត្រីមានសិទ្ធិគ្រប់គ្រាន់មកពិនិត្យ ? ។ បន្ទោស

ត្រង់នេះក៏មិនសមព្រោះការពិនិត្យ បានយកត្រឹមតែពីជំនាន់កណ្តាល គឺពីសតវត្សទី ១៤ មកសតវត្សទី ២០ ដែលច្បាប់ខ្មែរបានថោនះស្ត្រីជាអ្នកទទួលខុសត្រូវខ្លួនឯងរួចទៅហើយ ។ ប៉ុន្តែបន្ទាប់មក ឋានៈស្ត្រីខ្មែរមានការប្រែប្រួលប្រសើរបន្តិចម្តង ៗ ដែរ។ យើងកត់សំគាល់ឃើញថា មានសាលារៀនសំរាប់ស្ត្រី ឥតមានលាយបុរសជាមួយទេ ។ បុរស និង ស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និង ការគ្រប់គ្រងគ្រួសារ ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយ ប្រពន្ធមួយ ។ ជាមួយនេះ :

ក-ស្ត្រី មានសិទ្ធិបោះឆ្នោត ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ។ ចាប់ពីអាយុ ២០ ឆ្នាំឡើងទៅ គេអាចឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យជាតំណាងរាស្ត្រ ។ ចាប់ពីអាយុ ៤០ ឆ្នាំ ឡើងទៅ គេអាចឈរឈ្មោះជាសមាជិកព្រឹទ្ធសភា ។

ខ-ស្ត្រី មានសិទ្ធិបង្កើតសហជីព និង ចូលជាសមាជិកសហជីព ។

គ-ស្ត្រី មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ និង មានសិទ្ធិប្តឹងទៅតុលាការដោយខ្លួនឯង ។

ឃ-មានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួនផ្ទាល់ ។

ង-មានសិទ្ធិឈប់សំរាក នៅក្រោយពេល សម្រាលកូន

ដោយទទួលប្រាក់បៀវត្ស និង ដោយមានការធានារក្សា សិទ្ធិអតីត កាល និង អត្ថប្រយោជន៍សង្គមផ្សេង ៗ ទៀត ។

ច-ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវ កំចាត់ចោល ។

ខ្ញុំគ្រាន់តែស្រង់ចំណុចខ្លះ ៗ អំពីច្បាប់រដ្ឋធម្មនុញ្ញ ដែល ចែងសេចក្ដីដូចខាងលើ ដែលស្ដាប់ហើយគួរឲ្យកក់ក្ដៅ ពិរោះ មានជំនឿតាមប្រទេសយើង ជាប្រទេសអនុញ្ញាតឲ្យប្រជាពលរដ្ឋ មានសិទ្ធិសេរីភាពគ្រប់គ្រាន់ ។ យើងធូរចិត្ត ដកដង្ហើមស្រួល ឃើញពន្លឺព្រះអាទិត្យ សប្បាយ អណ្ដែតអណ្ដូង... តែដល់ជើង មកជាប់ដីវិញ ចិត្តក្ដី ទេសភាពក្ដី ប្រែជាងងឹត អាប់រស្មី ។ តើ ស្ត្រីខ្មែរ ដែលសព្វថ្ងៃនេះ ភាគច្រើន ដែលត្រូវធ្វើអាជីពសំរាប់ ចិញ្ចឹមគ្រួសារ បានន័យថា ខ្លួនជាមេគ្រួសារ ត្រូវជួបប្រទះនឹង ឧបសគ្គគ្រប់បែបយ៉ាង ងងឹតមុខ រកផ្លូវដើរមិនឃើញ តើត្រូវធ្វើ យ៉ាងណា ដើម្បីនឹងបានប្រាក់រាល់ថ្ងៃ មកចិញ្ចឹមខ្លួនព្រមទាំង គ្រួសារ ? ។

រដ្ឋាភិបាល ដែលមានក្រសួងកិច្ចការនារី បានខំប្រឹងប្រែង បង្កើតមាត្រាច្បាប់ ចំនួន ២១ ដើម្បីបង្កើតការយល់ដឹងអំពីការរើស អើង ប្រឆាំងនឹងនារីភេទ ក្នុងគោលបំណង :

ទី១-ដើម្បីបង្កើតការយល់ដឹងជាសាធារណៈពីបទដ្ឋាន សិទ្ធិ

មនុស្ស ទាក់ទងនឹងការរើសអើង ប្រឆាំងនឹងនារីភេទ ។

ទី២-ដើម្បីធ្វើឲ្យប្រសើរឡើង នូវយន្តការអនុវត្តសិទ្ធិមនុស្ស របស់នារីដែលមានស្រាប់ ។

ទី៣-ដើម្បីពង្រឹង និង ជំរុញឲ្យមានការផ្លាស់ប្តូរ នៅក្នុងច្បាប់នានា ដែលមានការរើសអើង នៅក្នុងការអនុវត្តន៍ជាក់ស្តែង។

ទី៤-ដើម្បីធ្វើឲ្យប្រសើរឡើងនូវយន្តការនានា ដែលមានស្រាប់ក្នុងការអនុវត្តន៍សិទ្ធិមនុស្សរបស់កម្ពុជា ស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍ជាសកល ស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញាសិទ្ធិមនុស្សនានា របស់អង្គការសហប្រជាជាតិ ។

ខ្ញុំសូមបើកវង់ក្រចក ជំរាបពីស្ថិតិ ចេញពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថា នៅឆ្នាំ ២០០៧ អ្នករកស៊ីផ្លូវភេទ មានចំនួន ១១.០០០ នាក់ នៅឆ្នាំ ២០០៨ ជិត ២០.០០០ នាក់ ឆ្នាំ ២០០៩ (យើងទើបនឹងខែ ៩) មានចំនួន ៣០.០០០ នាក់..... គឺវាកើនឥតស្រាកស្រាន្ត ។

ច្បាប់ថែមលើច្បាប់ ដើម្បីពន្យល់ បំភ្លឺទៅលើការប្រឆាំង និងការរើសអើង ប្រឆាំងនឹងនារីភេទ ! តើវាមានប្រសិទ្ធភាពលើអ្នកអនុវត្តច្បាប់ឬទេ ? ។

តើរដ្ឋាភិបាល មានគិតថា អ្វីៗដែលកើតឡើងប្លែកៗក្នុងសង្គមក៏ដោយសារក្រពះវាទារ គឺការអត់ឃ្លាន ឬក៏ដោយសារខ្វះ-

ការអប់រំ ។ សតវត្សណាក៏ដោយ តែងមានបញ្ហាក្រពះ តែចំណងគ្រួសារ មិនដែលបែកបាក់ដូច្នេះទេ ។ ខ្ញុំយល់ឃើញថា ពិភពលោកដើរទៅមុខជារៀងរាល់ថ្ងៃ ។ តែទោះបីយ៉ាងណាក៏ដោយ គ្រួសារនៅតែមាន ឯការអប់រំក្នុងគ្រួសារ គឺឪពុក ម្ដាយជាគំរូឲ្យកូន ចៅ ធ្វើតាមដោយមានការស្រឡាញ់ គោរព ឪពុកម្ដាយ វិញ ក៏មានមេត្តា ករុណា ស្រឡាញ់កូន តាមរបៀបប្រៀនប្រដៅ ជាទំនៀមទម្លាប់ កេរ្តិ៍តំណែលពីដូនតាមក តើទំនៀមទម្លាប់នេះ បាត់ទៅណាអស់ទៅ ? ។

ឪពុក ម្ដាយ មានករណីយកិច្ចរបស់ខ្លួនយ៉ាងច្បាស់ ។ កូនក៏មានករណីយកិច្ចរបស់ខ្លួនយ៉ាងច្បាស់ដែរ បើចំណងគ្រួសារមានហើយ តើការបែកខ្ញែកគ្រួសារ អាចកើតមានបានឬទេ ? ។ ត្រង់ចំណុចនេះ ខ្ញុំចង់និយាយថា តើកូនស្រី អាចដាច់ចិត្តចេញពីផ្ទះ ទៅធ្វើផ្ដេសផ្ដាសបានឬទេ ? តើ ឪពុក ម្ដាយ អាចបិទភ្នែកឲ្យកូនស្រីនៅវ័យក្មេង បែកចេញពីខ្លួនបានឬទេ ? នេះ ជាករណីយកិច្ចមួយ ដែលត្រូវប្រើពេលវេលាយូរអង្វែងណាស់ ដើម្បីឲ្យការអប់រំ ជាមរតកពីដូនតា អាចមានពន្លកធំធាត់ឡើង ។

សំណួរមួយទៀត គឺថា តើអ្វីជាជំហរមូលដ្ឋាននៃរដ្ឋនីមួយ ៗ ? ។ ដំបូងបំផុត គឺប្រជាពលរដ្ឋម្នាក់ ៗ ។ ប៉ុន្តែ តើប្រជាពលរដ្ឋនោះមកពីណា ? ។ គឺមកពីគ្រួសារ ។ គ្រួសារ

ទាំងអស់ រួមគ្នាជាប្រជាពលរដ្ឋ ទាំងអស់ ។

រដ្ឋនឹងមានកំឡាំង ក៏អាស្រ័យប្រជាពលរដ្ឋ ជាអ្នកចេះដឹង មិនមែនជាមនុស្សល្ងង់ខ្លៅ ឥតចេះលេខអក្សរអ្វីនេះទេ ។ ប្រជាពលរដ្ឋ ជាអ្នកចេះដឹង ខួរក្បាលក៏ភ្លឺស្វាង ចេះគិតពិចារណា មិនឆាប់ជឿ ជួច្នេះ ឥតចាញ់បោកគេដោយងាយ ៗ នោះទេ ។ ម្យ៉ាងទៀត ក្នុងការរស់នៅ ក៏គ្នាចេះលៃលកដោះស្រាយ មិនផ្តេកផ្តួលទៅលើព្រេងវាសនា ។

សូមព្រះតេជគុណ អ្នកស្រី លោក មេត្តាពិចារណាហើយ ឲ្យចម្លើយតាម ព្រះតេជគុណ អ្នកស្រី លោក យល់ចុះ ។

ខ្ញុំសូមអរព្រះគុណ សូមអរគុណ ! ៕

# សិទ្ធិរបស់ស្ត្រី នៅក្នុងព្រះពុទ្ធសាសនា

ខ្ញុំព្រះករុណា ខ្ញុំ សូមគោរពអង្គសិក្ខាសាលា សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមធ្វើសេចក្តីគោរពរាប់អាន ចំពោះបងប្អូនទាំងអស់ ដែលមកជួបជុំគ្នាក្នុងទីនេះ ។

ខ្ញុំ នឹងអធិប្បាយអំពីសិទ្ធិស្ត្រី នៅក្នុងព្រះពុទ្ធសាសនា ។ លោកស្រីទាំងពីរនាក់ គាត់បានអធិប្បាយយ៉ាងក្បោះក្បាយ ពីសិទ្ធិស្ត្រីនានា ។ ដើម្បីឲ្យឃើញច្បាស់ ពីទស្សនៈស្ត្រីក្នុងព្រះពុទ្ធសាសនា ខ្ញុំនឹងបង្ហាញខ្លី ។ ពីទស្សនៈស្ត្រី នៅក្រៅព្រះពុទ្ធសាសនា សិន សិទ្ធិស្ត្រី មានន័យថា ការជំនាញ ភាពពូកែ ឬ ភាពមានប្រាជ្ញាវាងវៃ ដែលស្ត្រីមានសមត្ថភាព សម្រេចធ្វើអ្វីមួយបានយ៉ាងប្រសើរ ។

## ផ្នែកអាណាចក្រ ក្រៅព្រះពុទ្ធសាសនា

គេមិនបានគិតគូរសិទ្ធិរបស់ស្ត្រី គេទុកស្ត្រីជាភាពទន់ខ្សោយសម្រាប់ប្រើការនៅក្នុងផ្ទះ ។ ពេលមានប្តី ឪពុក ម្តាយ មិនចែកទ្រព្យសម្បត្តិឲ្យកូនស្រីទេ នាងព្រាត់ប្រាសពីញាតិរបស់ខ្លួនទាំងនៅក្មេង រស់នៅត្រកូលខាងប្តី បំរើគេដូចជាទាសីដាច់ថ្លៃ ពេលប្តីស្លាប់ គេបង្គាប់ប្រពន្ធ ឲ្យសុខចិត្តស្លាប់ទៅតាមប្តី បើមិនធ្វើតាម គេនាំគ្នាបោះក្នុងភ្លើង ឬ កប់ទាំងរស់ បើយើងមិនយល់ព្រមទេ រស់នៅជាស្ត្រីមេម៉ាយ សង្គមគេមិនរាប់អានឡើយ ។ ពេល

កើតមក បើគេឃើញកូនជាស្រី ឳពុក ម្តាយ មិនសប្បាយចិត្ត ព្រោះមិនអាចជាប់ត្រកូល ហៅថាដាច់សែ ។ សព្វថ្ងៃនេះ ប្រទេសខ្លះ ស្ត្រីចូលធ្វើការ គេមិនឲ្យប្រាក់ខែ ស្មើនឹងបុរសទេ និងមិនឲ្យសិទ្ធិស្ត្រី បោះឆ្នោតជាដើមផង ។ ឯការស្លៀកពាក់វិញ បើបុរសជាប្តី មិនអនុញ្ញាតទេ ស្ត្រីខ្លះគ្មានសិទ្ធិស្លៀកពាក់ តាមបំណងរបស់ខ្លួនឡើយ ។

## ចំណែក បុរសវិញ មានសិទ្ធិច្រើនណាស់

គេទុកបុរស ជាកូនរបស់ព្រះជាម្ចាស់ ទោះបីបុរសនោះ ប្រព្រឹត្តមិនជាប្រយោជន៍ ឬ ធ្វើអកុសលកម្មណាមួយ ក៏ទៅឋានសួគ៌បានដែរ ។ បុរសមានសិទ្ធិសិក្សាព្រះគម្ពីរ ធ្វើពិធីផ្សេង ៗ ខាងសាសនាបាន ឯស្ត្រីវិញ មិនអាចសិក្សាព្រះគម្ពីរបានទេ សូម្បីធ្វើបុណ្យ ទៅឋានសួគ៌ខ្លួនឯងមិនបានផង តែគេអាចទៅឋានសួគ៌បាន តាមរយៈស្តាប់បង្គាប់ប្តី និង បំរើប្តី ។ សារុបសេចក្តីទៅ ស្ត្រីគ្មានសិទ្ធិ គ្មានតម្លៃអ្វីសោះ គួរឲ្យអាសូរស្ត្រីណាស់ ។

## មតិក្នុងព្រះពុទ្ធសាសនា

មតិខាងលើនេះ ផ្ទុយស្រឡះពីព្រះពុទ្ធសាសនា ។ ព្រះពុទ្ធសាសនា មិនឲ្យតម្លៃមនុស្ស ដោយសារកំណើត ភេទ វណ្ណៈនោះទេ ។

បើគេធ្វើអាក្រក់ដោយ កាយ វាចា ចិត្ត ត្រូវធ្លាក់ទៅអបាយភូមិ នរក តិរច្ឆាន ប្រេត អសុរកាយ ។ បើគេធ្វើអំពើល្អ ដោយ កាយ វាចា ចិត្ត ទៅកើតឋានសួគ៌ គ្មាននរណា ពិសេស ជាង នរណាទេ គឺស្មើគ្នាដោយកម្ម គឺ អំពើរបស់គេនេះឯង ។

ព្រះពុទ្ធ ឲ្យតម្លៃមនុស្សទៅតាមគុណធម៌ ដែលម្នាក់ៗប្រព្រឹត្ត និងទៅតាមកម្មដែលខ្លួនកសាង ឧទាហរណ៍ នាងមល្លិកា ជាស្ត្រី បេះផ្កាលក់ ប៉ុន្តែ ដោយកម្ម គឺអំពើល្អរបស់នាង នាងបានជា មហេសី ព្រះបាទបសេនទិ ។ ក្នុងពេលព្រះនាងកំពុងប្រសូតបុត្រ ព្រះបាទបសេនទិ កំពុងគាល់ព្រះសម្មាសម្ពុទ្ធ នៅវត្តជេតពន ពេលនោះ អាមាត្យចូលទៅថ្វាយដំណឹងថា ព្រះមហេសី ប្រសូត បានព្រះរាជបុត្រីហើយ ព្រះបាទបសេនទិ ទ្រង់ព្រះសណ្ដាប់ដូច្នោះ ហើយ បែបជាអន់ព្រះទ័យ (សូមបងប្អូនចាំស្ដាប់ ពុទ្ធដីកា ល្អ ពិសេសបំផុត) ពេលនោះ ព្រះពុទ្ធ ទ្រង់ត្រាស់ថា (បពិត្រមហា រាជ ស្ត្រីក៏ប្រសើរដែរ សូមព្រះអង្គ ចិញ្ចឹមឲ្យបានល្អ ស្ត្រីមាន បញ្ញា មានសីល គោរពមាតា បិតា គោរពប្ដី បុត្រីនេះ សមគួរ នឹងគ្រប់គ្រងផែនដីបាន) (ល្អណាស់ពាក្យនេះ) ។ សេចក្ដីនេះ បញ្ជាក់ថា ព្រះពុទ្ធ មិនបន្ថោកបន្ទាបស្ត្រីទេ ព្រះអង្គ ឲ្យតម្លៃស្ត្រី ដូចជាបុរសដែរ ។

ម្យ៉ាងទៀត ក្នុងធម៌ទិសទាំង ៦ ព្រះពុទ្ធ សំដែងថា ស្ត្រី និង

បុរស ជាទិសមួយ ដែលគួរគោរព ។ ដើម្បីចំណងមេត្រីភាព ត្រជាក់ផ្សាយទៅដោយមេត្តា ករុណា ព្រះពុទ្ធ ឲ្យប្ដីប្រតិបត្តិចំពោះ ប្រពន្ធ ដោយធម៌ ៥ យ៉ាងគឺ :

១-រាប់អានភរិយា ឲ្យតម្លៃ លើកតំកើង ថាជាភរិយា ពេញមុខ

២-មិនមើលងាយស្ត្រី ដែលជាភរិយាឡើយ

៣-មិនប្រព្រឹត្តក្បត់ចិត្ត ភរិយា

៤-ប្រគល់ភាពជាធំ ដល់ភរិយានៅក្នុងការងារផ្ទះ

៥-រកប្រដាប់កាយ (គ្រឿងអលង្ការ) ឲ្យភរិយាតាមឱកាស។

ចំណែកឯភរិយាវិញ ត្រូវប្រតិបត្តិ ចំពោះប្ដី ដោយធម៌ ៥យ៉ាង គឺ :

១-ចាត់ចែងការងារផ្ទះ ឲ្យបានរៀបរយ

២-សង្គ្រោះញាតិទាំងពីរខាង ខាងខ្លួនឯង និង ខាងស្វាមី

៣-មិនក្បត់ចិត្តស្វាមី

៤-ខំរក្សាទ្រព្យសម្បត្តិ ដែលប្ដីរកបានមក

៥-ឧស្សាហ៍ មិនខ្ជិលច្រអូសក្នុងការងារទាំងពួង ។

គោលធម៌ដែលព្រះពុទ្ធ បានរៀបចំនេះ ជាការឲ្យតម្លៃ និង ជាគ្រឹះមួយ ដែលជួយសង្គមគ្រួសារ ឲ្យចេះរួបរួមគ្នា ដោយសុខ សួស្ដី នេះជាសក្ខីភាពផ្ដល់សិទ្ធិដល់ស្ត្រីយ៉ាងធំ ព្រោះក្នុងសម័យ

កាលនោះ បុរសមានសិទ្ធិខ្លាំងណាស់ ។

ម្យ៉ាងទៀត ចំពោះស្ត្រីភេទ ក្នុងព្រះពុទ្ធសាសនា ស្ត្រីជាភេទទន់ខ្សោយ នៃរូបរាងកាយតាមច្បាប់ធម្មជាតិ ប៉ុន្តែ ខាងសតិបញ្ញា ស្ត្រីភេទ មានកំរិតស្មើនឹងបុរសដែរ អាចសម្រេចមគ្គ ផលដូចបុរសដែរ ក្នុងសម័យកាលនោះ មានស្ត្រីជាច្រើន បានសម្រេចមគ្គ ផល និង បានទទួលតំណែងជា ឯតទគ្គ ទៀតផង (La championnne) ។

ភិក្ខុនី ឧប្បលវណ្ណា មានឫទ្ធិ ដូចជាព្រះមោគ្គល្លាន ភិក្ខុនីខេមា យាងតាមអាកាស ហើយឈរលើអាកាស ថ្វាយបង្គំព្រះ (ដោយពេលនោះ មានទេវតា មកយ៉ាងច្រើន ដើម្បីគាល់ព្រះពុទ្ធ ដោយគ្មានកន្លែង ក៏នាងឈរលើអាកាស ដើម្បីថ្វាយបង្គំ) នាងបដាចារ ជា ឯតទគ្គ ទ្រទ្រង់ព្រះវិន័យ ដូចព្រះឧបាលិ ។ ក្រៅពីនេះ សូម្បីស្ត្រីមេម៉ាយ ដូចជានាងឧត្តរានន្ទមាតា គ្មានញាតិគេរាប់អាន នាងរៀនចេះចាំគាថា ២៥០ មានការសរសើរពីស្តេចទេវតា នាមវេស្សវ័ណ ថា នាងចេះចាំគាថាត្រឹមត្រូវ ដូចការសំដែងរបស់ព្រះពុទ្ធ ។ ឯនាងបុណ្ណា ជាទាសីរបស់អនាថបិណ្ឌិកសេដ្ឋី ហ៊ានឃាត់ព្រះពុទ្ធ ឲ្យគង់ចាំព្រះវស្សា នៅវត្តជេតពនទៀត ។ ព្រះពុទ្ធ ទ្រង់រាប់អាន លើកតម្កើងស្ត្រីទាំងពីរប្រភេទនេះ ដូចជាស្ត្រីឯទៀតដែរ ។

ថ្វីត្បិតតែសព្វថ្ងៃនេះ ភិក្ខុនី គ្មានក៏ដោយ តែអត្ថន័យ ភិក្ខុនី នៅតែដដែល ។ ភិក្ខុ ឬ ភិក្ខុនី បានន័យថា អ្នកដែលឃើញ ភ័យក្នុងវដ្តសង្សារ សូម្បីតែសិក្ខាបទរបស់ភិក្ខុ មាន ២២៧ តិចជាង សិក្ខាបទភិក្ខុនី មានដល់ ៣១១ ក៏ដោយ នេះគ្រាន់តែការរៀបចំ សាសនារបស់ព្រះអង្គ ឲ្យស្ថិតនៅយូរតែប៉ុណ្ណោះ ។

សព្វថ្ងៃនេះ ក្នុងពិភពលោក គេកំពុងទាមទារសិទ្ធិស្ត្រី កំពុងលើកតម្កើងស្ត្រី ឲ្យមានតម្លៃ ឲ្យស្ត្រីមានសិទ្ធិ ស្មើនឹងបុរស ដែរ ។ ស្ត្រី មានបញ្ញា ធ្វើជាអ្នកដឹកនាំប្រទេស បើកអាកាស យាន ធ្វើការក្នុងយានអវកាស ធ្វើមេបញ្ជាការផ្នែកកងទ័ពទៀត ផង ។ល។ នេះ ទុកជាស្ត្រី មានសមត្ថភាពត្រឹមត្រូវ ជាការល្អ ប្រសើរណាស់ហើយ ប៉ុន្តែ សូមជ្រាបថា នេះគ្រាន់តែជាសិទ្ធិ ខាងក្រៅតែប៉ុណ្ណោះ ។ ចំណែកព្រះពុទ្ធ ព្រះអង្គ បានផ្តល់សិទ្ធិ ឲ្យស្ត្រី អប់រំបណ្តុះបញ្ញា ឲ្យស្ត្រីចាក់ធ្លុះ ឃើញសច្ចទាំងបួន អាច សម្រេចមគ្គ ផល បាន ដូចបុរសដែរ នេះចាត់ជាសិទ្ធិខាងក្នុង ជា សិទ្ធិប្រសើរខ្ពង់ខ្ពស់បំផុត ផុតភ្លើងទុក្ខ ភ្លើងកិលេសគ្រប់យ៉ាង ដែលមិនមានបុគ្គលណា ឬ សាស្តាណា អាចផ្តល់សិទ្ធិប្រភេទនេះ ដល់ស្ត្រីបានដូចព្រះពុទ្ធឡើយ ។ ពួកស្ត្រី ដែលបានទទួលសិទ្ធិ ខ្ពង់ខ្ពស់នេះ តែងតែពោលសរសើរហើយ សរសើរទៀត មិនចេះ ចប់ ថាពិតជាសិទ្ធិដ៏ថ្លៃថ្លាមែន ។

ខ្ញុំព្រះករុណា ខ្ញុំ បានចាំពាក្យស្លោកមួយឃ្លាថា :

(សំណាបយោងដី ស្ត្រីយោងបុរស) (សុំទោស) តាមអក្សរសិល្ប៍រឿងមាយើង នាងជាភរិយា បានសម្រេចចិត្ត យោងមាយើងជាប្តី តាំងពីនៅជាបុរសកំសត់ ដើរជញ្ជាត់ត្រី រហូតដល់ទៅបំរើព្រះរាជាបាន ហេតុនេះ ខ្ញុំសូមឲ្យបុរស ដែលមានភរិយាជ្រះថ្លាក្នុងគុណព្រះរតនត្រៃ មុន សូមធ្វើខ្លួនឲ្យស្រោល ដើម្បីឲ្យភរិយាយោង ពីមិច្ឆាទិដ្ឋិ មកជា សម្មាទិដ្ឋិ ដូចជានាងវិសាខា ឬនាងចុល្លសុភទ្រា ជាកូនស្រីអនាថបិណ្ឌិកសេដ្ឋី មានសិទ្ធិយោងគ្រួសារខាងប្តីទាំងអស់ ឲ្យព្រមស្តាប់ព្រះធម៌ ពុទ្ធសាសនា និង ចេះគោរពគុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទៀតផង នេះជាសំណូមពររបស់ខ្ញុំ ។

នៅទីបញ្ចប់ ខ្ញុំសូមអំពាវនាវ ដល់ស្ត្រីដែលមានទុក្ខ ឬបំរុងនឹងមាន ទារុណកម្មខាងផ្លូវចិត្ត តាមរបៀបណាមួយក៏ដោយសូមចូលមករកវិធី អប់រំផ្លូវចិត្តក្នុងព្រះពុទ្ធសាសនា ដែលជាវិធីមួយសមហេតុ ផល ដើម្បីរំលត់ភ្លើងទុក្ខនានា ដែលឆេះគគុក នៅក្នុងចង្ក្រាន គឺរូបកាយនេះ តាមវិធីយើងមិនបន្ថែមអុស តើអុសគឺជាអ្វី ? អុស គឺជាលោកធម៌ទាំងប្រាំបី ដែលបង្វិលយើងសព្វ ៗ កាល ដូចព្រះពុទ្ធដីកាថា :

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**

## អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ

បានន័យថា ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មិនមានរាគៈ ១ មានចិត្តដ៏ក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

ឯការអប់រំចិត្តនេះ យើងធ្វើសន្សំម ។ ស្ថិតនៅក្នុងសេចក្តីព្យាយាម កិលេសក៏រលាយបន្តិចម្តង ។ តាំងពីកិលេសគ្រោតគ្រាតរហូតដល់កិលេសល្អិត ។ យើងក៏អាចកំចាត់បានតាមលំដាប់ ពេលនោះហើយ ពន្លឺនៃចិត្ត ភាពហ្នឹងននៃចិត្ត ក៏កើតជាមួយគ្នាបន្តិចម្តង ។ ដែរ ។

នេះ ជាលក្ខណៈមួយ ដែលយើងពឹងខ្លួនដោយខ្លួនឯង សូមស្ត្រីទាំងឡាយ កុំមើលស្រាលពីសមត្ថភាពរបស់ខ្លួនឲ្យសោះ អ្នកដែលព្រមសិក្សាព្រះធម៌ ព្រះធម៌ ប្រាកដជានឹងជួយយើងវិញមិនខានឡើយ ៕

ដោយ ឧបាសិកា ឌី សាមារ៉ាន់

## ទាន ដែលព្រះពុទ្ធ មិនរាប់ថាជាទាន

-យើងខំធ្វើទានព្រោះចង់បានផល
ទានខ្លះមិនផ្តល់ឲ្យផលតបត
ឲ្យស្រីទៅប្រុសទាននោះនាំវរ (វឹកវរ)
ទានមិននាំមកក៏នូវផលបុណ្យទេ ។
-ឲ្យទានគោញីដល់សត្វគោឈ្មោល
សត្វលោតកញ្ច្រោលបោលរត់តាមមេ
ទានគ្មានប្រយោជន៍ពាក្យពីបុព្វេ
ដឹកនាំកាមេ មិនបានក្តីសុខ ។
-បើអ្នក ឲ្យទានជាទឹកស្រវឹង
ពិតជាអ្នកប្រឹងខំរកទំនុក
នាំពួជប្រមាទចូលដួចបើកផ្នុក
ទ្រព្យផងធ្លាក់ខ្ទុកពីព្រោះតែស្រា ។
-ឲ្យទានមហោស្រពរ បាំច្រៀងរាំ
ប្រគំ ទន្ទ្រាំ ញ័រញាក់កាយា
ទានគ្មានបានផលហិនថវិកា
មុនធ្វើពិចារណាកុំចេះតែស្មាន ។
-គូររូបប្រុសស្រីវិចិត្រយ៉ាងល្អ
មានចិត្តអំណរយកធ្វើជាទាន
មិនមានផលទេព្រោះព្រះទ្រង់ញាណ
ចាត់ទុកជាទាន បង្កើនកាមេ ៕

# សិទ្ធិស្ត្រី នៅទ្វីបអឺរ៉ុប

ដោយលោកស្រី មាស សេដ្ឋា ភរិយា លោក ឧុក រ៉ាស៊ី

១-ពីអតីតកាល មកបច្ចុប្បន្នកាល

ក្នុងកាលដំបូងនៃប្រវត្តិសាស្ត្រអឺរ៉ុប តួនាទីធំបំផុត របស់ស្ត្រី គឺអ្វីដែលហៅថា ការងារនៅផ្ទះ មានជាអាទិ៍ គឺការរៀបចំ សំអាតផ្ទះសម្បែង និង ការថែរក្សាដំណើរការល្អ នៃ គ្រួសារទាំងមូល ។ ជាទូទៅ ស្ត្រីទទួលខុសត្រូវ គ្រប់គ្រងដំណើរការផ្ទះ ការកាត់ដេរខោអាវ ឬ ធ្វើឧបករណ៍សំរាប់ផ្ទះ សំរាប់ស្រែចំការខ្លួន និងការលក់ដូរភោគផល នៃ ស្រែចំការនោះ ។ល។ គេបានអប់រំ ស្ត្រី សំរាប់តែបំពេញការងារនៅផ្ទះប៉ុណ្ណោះ ដែលជាការងារចាំបាច់ សំរាប់ការដុះដាល និង សេចក្ដីចំរើននៃក្រុមគ្រួសារនីមួយ ៗ។ ចំណុចនេះ បានបង្ហាញច្បាស់ថា គេបាន ជំរិតយកប្រយោជន៍អំពី ស្ត្រី ដល់កំរិតណា ទោះក្នុងរឿងការងារ និង ក្នុងករណីនៃការបន្តពូជពង្សក្ដី ។ ជំនាន់អតីតកាលនោះ ផលនៃការងារ និង ផល ដែលទាក់ទង និង ភេទស្ត្រី ត្រូវបានទទួលការត្រួតត្រា តាមឆន្ទៈ របស់បុរស ដែលមានប្រៀបជាងស្ត្រី ជានិច្ច ។

-ការរកមនុស្សស្រីជាបន្ទាន់ ឲ្យជួយក្នុងពេលលំបាក : ពីចលនារំដោះស្ត្រី ទៅរកសិទ្ធិរបស់ស្ត្រី នាដើម ស.វ. ទី ២០ ក្រោយពីសង្គ្រាមធំលើកទី ១ (១៩១៤-១៩១៨) ការប្រយុទ្ធ សំរាប់

សិទ្ធិស្ត្រី ហើយគេត្រូវការស្ត្រី យ៉ាងប្រញាប់បន្ទាន់ ដើម្បីឲ្យសេដ្ឋកិច្ចដើរ ។ នៅ អឺរ៉ុប គេរើសបេក្ខជនស្ត្រី ឲ្យទៅធ្វើការផ្សេង ៗ ដូចជាអ្នកយាមឆ្នេរសមុទ្រ អ្នកធ្វើការជំនួយពេទ្យ ធ្វើស្មៀន ធ្វើការក្នុងរោងឧស្សាហកម្ម ធ្វើគ្រាប់កាំភ្លើង និង ធ្វើសម្ភារៈសំរាប់កប៉ាល់ជាដើម ។ ក្នុងជំនាន់នោះហើយ ដែលចលនារំដោះស្ត្រី (Emancipation féminine) ក៏មានឥទ្ធិពលខ្លាំងដែររហូតដល់មានពាក្យថា (តើសង្គ្រាមធំឬ ? ដែលនាំចលនារំដោះស្ត្រីឲ្យទៅមុខ) ។ ចលនាសន្តិភាពបានថែងថា (មនុស្សប្រុសជាបុព្វហេតុ នៃ សង្គ្រាម និង យោធានិយម រីឯ ស្ត្រី ដោយមានសភាវនីតិ ជាម្តាយ តែងស្រឡាញ់សន្តិភាព) ។

ក្រោយពីពេលនោះមក ស្ត្រីនៅគ្រប់ទិសទី បានរួមគ្នា ធ្វើការតវ៉ា យកសិទ្ធិបោះឆ្នោតផ្ទាល់ខ្លួន (មិនបាច់សុំការអនុញ្ញាត ពីឪពុក ឬ ប្តី) ។ ការទាមទារនេះ បានធ្វើឡើងដោយការប្រជុំគ្នាធ្វើសិក្ខាសាលា ជាសាធារណៈ ធ្វើញត្តិ ឬ ធ្វើបណ្តឹងទៅអាជ្ញាធរផ្សេង ៗ មានរដ្ឋាភិបាល និង តុលាការ ជាដើម ។

សព្វថ្ងៃនេះ (សតវត្សទី ២១) សិទ្ធិសំខាន់ ៗ ពិសេសសំរាប់ស្ត្រី មានចងក្រងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ ឬ អនុសញ្ញា ពីសំណាក់សហគមន៍ អឺរ៉ុប អ.ស.ប. និងក្នុងអង្គការអន្តរជាតិមានសាលាក្តីខាងយុត្តិធម៌ នៅទីក្រុងឡា អេ (La Haye) ជាដើម ។

សមភាពរវាងស្ត្រី និង បុរស មានក្នុងគោលការណ៍ច្បាប់ហើយ ។ ប៉ុន្តែ ក្នុងការជាក់ស្តែង វានៅតែមានការប្រព្រឹត្ត ប្រកបដោយទម្ងន់ពីរ និង ខ្នាតពីរ ជានិច្ច ។ ស្ត្រី តែងទទួលប្រាក់ខែ ឬ ប្រាក់បំណាច់ការងារ តិចជាងបុរស ប្រមាណ ជិត ២០% ទោះគេមានសមត្ថភាពដូចគ្នាក្តី ។ ស្ត្រីតិចណាស់ ដែលបានកាន់តំណែង ជាអ្នកដឹកនាំកិច្ចការក្នុងសហគ្រាស ក្នុងរដ្ឋការ ឬ ក្នុងនយោបាយ ។ ការពិបាករបស់ស្ត្រី ក្នុងការរ៉ាប់រងការងារវិជ្ជាជីវៈផង និង ករណីយកិច្ច ជាមេផ្ទះផង ក៏នៅតែធ្ងន់ធ្ងរដដែល មិនទាន់មានការដោះស្រាយគ្រប់គ្រាន់ទេ ។

២-សិទ្ធិស្ត្រី តាមគោលការណ៍ច្បាប់ នៅអឺរ៉ុប មានពីរចំណែក

ក-សិទ្ធិ ជាបុគ្គល (ដូចគ្នានឹងបុរស)

ខ-សិទ្ធិ ពិសេស សំរាប់ភេទស្ត្រី (ក្នុងការជ្រើសរើសមាតុភាព ការជ្រើសរើសមុខវិជ្ជាជីវៈ និង ជីវភាពគ្រួសារ ការការពារទល់នឹងអំពើហឹង្សាផ្សេង ៗ មកលើខ្លួន ការទាមទារភាពស្មើគ្នាក្នុងវិស័យនយោបាយ) ។

យោងតាមធម្មនុញ្ញនៃច្បាប់មូលដ្ឋាន ក្នុងសហភាព អឺរ៉ុប មាត្រាទី ២៣ បានចែងថា :

សមភាពរវាងបុរស និង ស្ត្រី ត្រូវមានក្នុងគ្រប់វិស័យ រាប់បញ្ចូលតាំងពីការរកការងារធ្វើ ការធ្វើការងារ និង ការទទួលប្រាក់

បំណាច់អំពីការងារ ។ គោលការណ៍សមភាពនេះ មិនត្រូវមានការជំទាស់ ពីមាត្រាផ្សេង ៗ ទៀត ដែលស្តីពីគុណប្រយោជន៍ពិសេស សំរាប់ស្ត្រីភេទ ដែលជាអ្នកភាគតិច (ក្នុងមជ្ឈដ្ឋានការងារ)ទេ ។

ការអនុម័តមាត្រានេះ បានធ្វើឡើងបន្ទាប់ពីការតវ៉ារបស់អង្គការស្ត្រីជាច្រើន ដែលបានសង្កេតឃើញជាអាទិ៍ថា :

-ស្ត្រី បានទទួលប្រាក់បំណាច់ការងារ តិចជាងបុរស ប្រមាណ ជាមធ្យម ១៧,៤ ភាគរយ ក្នុងមុខការងារដូចគ្នា ។

-ស្ត្រី តែងបានការងារតូចតាច មិនមាំមួន មិនស្ថិតស្ថេរ ច្រើនជាងបុរស ហើយច្រើនត្រូវទទួលផលវិបាកអាក្រក់ ខ្លាំងជាងបុរស នៅពេលណាមានវិបត្តិសេដ្ឋកិច្ច តូចក្តី ធំក្តី ។

-ស្ថិតិ នៃ ភាពឥតការងារធ្វើ (ដោយថ្ងៃថ្នូរ) របស់ស្ត្រី តែងតែមាន ធំជាងខាងបុរស ។ នៅខែមករា ២០០៧ ស្ត្រីអឺរ៉ុប ដែលអត់ការងារធ្វើ មាន ៨,៥ ភាគរយ ចំណែកឯបុរស មានតែ ៦,៧ ភាគរយ ប៉ុណ្ណោះ ។

-ចំនួនស្ត្រី អឺរ៉ុប ដែលមានសញ្ញាប័ត្រ រហូតដល់ កំរិតមហាវិទ្យាល័យ បានកើនខ្ពស់ជាងបុរស គឺមាន ៥៩ ភាគរយ នៃអ្នកប្រកបការងារទាំងអស់ ។ ប៉ុន្តែ ស្ត្រីបានទទួលតំណែង ជាអ្នកដឹកនាំការងារ តិចជាងបុរស ហើយទទួលការងារ ដែលមាន

ប្រាក់បំណាច់ ទាប ៗ ទៅវិញ ។

-ក្នុងពេលនេះ ដែលប្រជាជនអឺរ៉ុប មានមនុស្សចាស់ ៗ កាន់តែច្រើនឡើង ៗ សហភាពអឺរ៉ុប ត្រូវការឲ្យស្ត្រី ចូលរួមធ្វើការ ឲ្យបានច្រើនថែមទៀត ជាពិសេស ក្នុងវិស័យបច្ចេកវិជ្ជា នៃពត៌មានសាស្ត្រ និង គមនាគមន៍សាស្ត្រ ។ នៅអឺរ៉ុប សំរាប់ឆ្នាំ ២០១០ គេនឹងមានការខ្វះខាតវិស្វករ ក្នុងវិស័យនេះ ចំនួនយ៉ាងតិច ៣០០.០០០ នាក់ ហើយសព្វថ្ងៃនេះ ក្នុងវិស្វករ ៥ នាក់ មានស្ត្រី តែ ១ នាក់ទេ ។

សហភាពអឺរ៉ុប បានគ្រោងទុកថា នៅឆ្នាំ២០១០ ចំនួនស្ត្រីក្នុងមជ្ឈដ្ឋានការងារ នឹងកើនដល់ ៦០ ភាគរយ គឺច្រើនជាងបុរស។

៣-បន្ទាត់គោលការណ៍ ប្រឆាំងនឹងអំពើហឹង្សាលើស្ត្រី

ក្រុមប្រឹក្សាអឺរ៉ុប បានអនុម័តនៅថ្ងៃ ៨ ធ្នូ ឆ្នាំ ២០០៨ មុននេះនូវបន្ទាត់ណែនាំថ្មី បន្ថែមលើសេចក្ដីអនុម័តពីមុន អំពីបញ្ហានេះ ។ គោលដៅនៃបទបន្ថែមនេះ ជាសញ្ញាឆន្ទនយោបាយ យ៉ាងច្បាស់លាស់ របស់សហភាពអឺរ៉ុប ដែលយកសិទ្ធិស្ត្រី ជាប្រធានបទសំខាន់ មានចារទុកក្នុងសកម្មភាព សង្គមជានិរន្តរ៍ ។

បទបញ្ហានេះ ផ្អែកទៅលើការសិក្សា ពិចារណាយ៉ាងល្អិតល្អន់ របស់ អ.ស.ប. នៅលើរឿងហឹង្សាគ្រប់បែបយ៉ាង ចំពោះស្ត្រី

(២០០៦) និង លើបញ្ហាស្ត្រី សន្តិភាព និង សន្តិសុខ (Femme, et Sécurité) (2008) និង ពីសហភាព អឺរ៉ុប ពីស្ថានភាព នៃ ស្ត្រី នៅក្នុងពេលមានចម្បាំង និង នាទីស្ត្រី ក្នុងការកសាងស្រុកឡើងវិញ និងកសាងលទ្ធិប្រជាធិបតេយ្យ ក្រោយពេលសង្គ្រាម ។

បទបញ្ញាចុងឆ្នាំ ២០០៨ នេះ មានទិសដៅសង្កត់ ទៅលើការអនុវត្តន៍គំរោងការជាក់លាក់ ដើម្បីស្ត្រី និង នារី ។

កិច្ចការនេះ បានទទួលការឧបត្ថម្ភពីអង្គការអឺរ៉ុប ខាងសិទ្ធិមនុស្ស ហើយនឹងការចូលរួមផងដែរ ពីអង្គការហិរញ្ញវត្ថុផ្សេង ៗ ទៀត ក្នុងអឺរ៉ុប និង រដ្ឋសមាជិកអឺរ៉ុប ។

យើងឃើញថា ការបង្កើតច្បាប់ និង ការអនុវត្តន៍ ដើម្បីការពារសិទ្ធិស្ត្រី នៅអឺរ៉ុបនេះ បានទទួលការជ្រោមជ្រែង ពីស្ថាប័នជាតិ និង អន្តរជាតិធំ ៗ ជាច្រើន មិនត្រឹមតែមកពីការទាមទារ នៃអង្គការមនុស្សធម៌តូចតាចទេ ។ ក្នុងប្រទេសគេនីមួយ ៗ រដ្ឋអំណាចគេ បានផ្តល់មធ្យោបាយគ្រប់យ៉ាង សំរាប់កិច្ចការពារហ្នឹង ។ ប៉ុណ្ណឹងហើយ ក៏នៅតែមានការរំលោភ មិនចេះចប់ដែរ ។

ពាក្យថា "អំពើហឹង្សាលើស្ត្រី" គឺអំពើទាំងឡាយ ដែលរំលោភលើស្ត្រីភេទ ដែលបណ្តាល ឬ អាចបណ្តាលឲ្យស្ត្រី មានខូចប្រយោជន៍ ឬ ខូចកិត្តិយស ឬ មានការឈឺចាប់ដល់ខ្លួនប្រាណ ដល់ភេទ ឬ ដល់សតិអារម្មណ៍ ។

ការរំលោភ មានរួមទាំងការគម្រាមកំហែង និង ប្រព្រឹត្តអំពើនោះ ការបង្ខិតបង្ខំតាមផ្លូវចិត្ត ឬ ការដកសិទ្ធិសេរីភាព ទោះបីក្នុងជីវភាព ជាសាធារណៈក្តី ឬ ក្នុងការរស់នៅជាឯកជនក្តី ។

គោលការណ៍ប្រឆាំង និង អំពើហឹង្សានេះ មានវិធី ៣ ដែលមិនអាចញែកចេញពីគ្នាបានគឺ ៖ ទី ១ ការបង្ការជាមុន (Mesures préventives), ទី ២ ការ ការពារ (Protection) និង ជួយឧបត្ថម្ភ ជនរងគ្រោះ (Soutien aux victimes) និង ទី ៣ ការប្តឹង ឲ្យផ្តន្ទាទោស (Poursuite) អ្នករំលោភ នោះ ។

-ការបង្ការជាមុន ត្រូវធ្វើឡើងដោយការផ្សព្វផ្សាយ តាមវិទ្យុ និង ទូរទស្សន៍ និង នៅកន្លែងសាធារណៈទាំងអស់ ដើម្បីពន្យល់អំពីស្ត្រីភាព និង លក្ខណៈនៃស្ត្រី អំពីដំណឹង នៃ ការប្រព្រឹត្តអំពើហឹង្សាលើស្ត្រី និង អំពើទណ្ឌកម្ម ដែលតុលាការបានដាក់លើអ្នកបានប្រព្រឹត្តអំពើនោះ ។ ដោយឡែក សហភាពអឺរ៉ុប ជួយពង្រឹង សមត្ថភាព ប្រទេសដែលជាសមាជិក ឲ្យធ្វើការត្រឹមត្រូវ និងជាក់លាក់ ថា ការហឹង្សា ទាំងប៉ុន្មាន ត្រូវតែទទួលទណ្ឌកម្ម ។

-ការ ការពារសិទ្ធិ និង ការជួយឧបត្ថម្ភ ជនរងគ្រោះ ត្រូវធ្វើដោយជំនួយពីអង្គការផ្សេង ៗ ដែលមានមធ្យោបាយ មិនមែនទុកឲ្យអ្នករងគ្រោះរ៉ាប់រង ធ្វើតែម្នាក់ឯងទេ ។

-ការផ្តន្ទាទោស នៃ អ្នករំលោភ ត្រូវធ្វើដោយបទបញ្ញត្តច្បាប់

យ៉ាងច្បាស់លាស់ ឥតមានលក្ខណៈ ស្រពិចស្រពិលទេ ចំពោះករណីនៃការរំលោភនីមួយៗ ។

ប្រទេសជាច្រើននៅអឺរ៉ុប បានខំរកគំនិតផ្សេងៗ មកប្រតិបត្តិ ដើម្បីបង្ក្រាបអំពើហឹង្សានេះ ដូចជាប្រទេស អេស្ប៉ាញ មានតុលាការពិសេស សំរាប់រឿងនេះ ។

ប្រទេស ស៊ុយអែត បានប្រកាសយ៉ាងច្បាស់ថា ការបំពានទៅលើស្ត្រី មិនត្រូវយកលេសថា មកអំពីទំនៀមទម្លាប់ ប្រពៃណី ឬមកអំពីអ្វីទៀត ដែលទាក់ទងនឹងសាសនា ។

គេថ្លែងដោយស្តាយថា នៅមានប្រទេសខ្លះ (Azerbaïdjan...) មិនបានចាត់ទុកថា ការរំលោភលើស្ត្រី ក្នុងគ្រួសារប្តី-ប្រពន្ធ ជាឧក្រិដ្ឋកម្ម ឬ ជាទោសកំហុសទេ ។

ទ្វីបអឺរ៉ុប បានរីកធំណាស់ ប៉ុន្តែ មិនទាន់មានវប្បធម៌ អឺរ៉ុប សំរាប់ប្រទេសទាំងអស់ទេ ។ ប៉ុន្តែ កិច្ចការ និង វិធានការ ដែលចាត់ការមកហើយ មិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ទេ ដើម្បីបំបាត់អំពើហឹង្សា ទាំងឡាយនោះ ។

នៅក្នុងទ្វីបអឺរ៉ុប ស្ត្រីជាង ១/៤ បានត្រូវទទួលភាពបំពានលើកាយយ៉ាងហោចណាស់ ក៏ម្តងដែរ ហើយ ១/១០ ត្រូវទទួលការរំលោភលើខ្លួនប្រាណ នេះ បើតាមសេចក្តីប្រកាសរបស់សាស្ត្រាចារ្យម្នាក់ នៅមហាវិទ្យាល័យ Osnabrick ស្រុកអាល្លឺម៉ង់ ។

បញ្ហានៃការរើសអើងចំពោះស្ត្រី ក៏ទើបនឹងមាន គេពិចារណាក្នុងពេលថ្មីនេះដែរ ។ គឺនៅឆ្នាំ ១៩៧៩ ទើបមានអនុសញ្ញា លើការបំបាត់ចោលនូវការរើសអើងគ្រប់បែបយ៉ាងចំពោះស្ត្រី ប៉ុន្តែ ក្នុងផ្នែកការងារ និង មុខរបរ អនុសញ្ញា ការពារអ្នកធ្វើការ ក្នុងការប្រឆាំងនឹងអំពើរើសអើងគ្រប់បែបយ៉ាង មិនត្រឹមតែរឿងប្រភេទនេះទេ គឺទាំងជាតិ សាសន៍ ពណ៌សម្បុរស្បែក មតិនយោបាយ ឬ ឋានៈក្នុងសង្គម បានធ្វើឡើងចាប់តាំងពីឆ្នាំ ១៩៥៨ មកម៉្លេះ ដោយអង្គការអន្តរជាតិ ខាងការងារ ។ ការរើសអើងចំពោះស្ត្រី ក៏ចេញមកពីការគេបន្ថោកសិទ្ធិសេរីភាពស្ត្រី ដែលក្លាយជាការប្រមាថចំពោះស្ត្រី ។

សេចក្តីបញ្ជាក់ :

នៅទ្វីបអឺរ៉ុប តួនាទីរបស់ស្ត្រី បានផ្លាស់ពីការទទួលខុសត្រូវក្នុងបញ្ហាផ្ទះសម្បែង មកការទទួលខុសត្រូវដល់ទៅពីរជាន់ គឺក្នុងបញ្ហាវិជ្ជាជីវៈផង និង ក្នុងបញ្ហាផ្ទះសម្បែងផង មានការអប់រំកូន ជាអាទិ៍ ។

នៅសម័យនេះ គេបានយល់ច្បាស់ថា គេត្រូវការពារសមភាពរវាងស្ត្រី និង បុរស នៅលើផ្នែកច្បាប់ ហើយតម្រូវឲ្យស្ថាប័នសង្គម និង ស្ថាប័នរដ្ឋទាំងអស់ ដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ

ឲ្យខិតខំអនុវត្ត គោលការណ៍នានា យ៉ាងប្រាកដប្រជា ។

ទោះជាយ៉ាងនេះក្តី បញ្ហាសិទ្ធិស្ត្រី នៅអឺរ៉ុប ក៏ភាគច្រើន ច្រើនតែនៅក្នុងទ្រឹស្តីនៅឡើយ ហើយក្នុងជីវិតជាក់ស្តែង គេនៅត្រូវការ សេចក្តីចំរើនក្នុងបញ្ហានេះ ឲ្យខ្លាំងគ្រាន់បើឡើង ជាងសព្វថ្ងៃនេះទៀត ។ សមភាពរវាងស្ត្រី និង បុរស នឹងកើតមានប្រាកដ គឺទាល់តែធ្វើយ៉ាងណា ឲ្យមនុស្សទទួលព្រមផ្លាស់ប្តូរ ចិត្តគំនិត (La mentalité) របស់ខ្លួនគ្រប់គ្នា មិនប្រកាន់ថាភេទណាទេ ។ នេះហើយជាបំណងធំបំផុត នៃអ្នកធ្វើច្បាប់ និង អ្នកអនុវត្តច្បាប់នៅទីនេះ ពីព្រោះគេយល់ច្បាស់ថា ការអនុវត្តន៍ និង កិច្ចអភិវឌ្ឍន៍នៃលោកសម័យនេះ និង ទៅអនាគត គេត្រូវការចាំបាច់នូវកម្លាំងទាំងអស់នៃសង្គមមនុស្សជាតិ ទាំងពីរភេទ ។

ខ្ញុំ សូមអរព្រះគុណព្រះសង្ឃ និង អរគុណ បងប្អូនទាំងអស់ ៕

# សំណួរ ចម្លើយ

ន៙ល

**សំណួរ** (អ្នកស្រី ឆោម ឆាយ លក្ខណា) តើអប់រំកូនរបៀបណា ដើម្បីឲ្យទៅជាទំពាំងស្នងឫស្សី ? ។

**ចម្លើយ** (អ្នកស្រី អ៊ុង តារាវិចិត្រ ចាយ) គ្រួសារខ្មែរយើង ដែលមករស់នៅប្រទេសបារាំងនេះ ភាគច្រើន គឺអ្នកដែលរត់គេចពីការកាប់សម្លាប់ដ៏ព្រៃផ្សៃ ប្រល័យពូជសាសន៍ របស់ខ្មែរក្រហម ។ ខ្មែរអ្នកមានចំណេះវិជ្ជា ចេះដឹងទំនៀមទម្លាប់ប្រពៃណី ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ជាច្រើន ។ អ្នកដែលរត់គេចមកនេះ ច្រើនតែជាអ្នកព្រាត់ប្រាស ប្តី ប្រពន្ធ បង ប្អូន កូន ចៅ ជាអ្នករងទុក្ខស្ទើរបាត់ស្មារតី ហើយអ្នកខ្លះ មិនបានរៀនសូត្រ មិនទាំងចេះអក្សរផង លុះបានមកដល់ស្រុកគេ ភាសាគេក៏មិនចេះទៀត អ្វី ៗ ក៏ប្លែកពីស្រុកយើងទាំងអស់ ម្ល៉ោះហើយ រឹតតែធ្វើឲ្យគេកើតទុក្ខ ពិបាកចិត្តថែមទៀត ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ គេក៏ចេះតែនាំគ្នាខំប្រឹងប្រែងតស៊ូ ដើម្បីចិញ្ចឹមជីវិតខ្លួនផង ដើម្បីអនាគតកូនចៅផង ។ ឯវិធីអប់រំកូន គឺគេត្រូវបង្ហាត់បង្រៀនឲ្យកូនចេះភាសាជាតិខ្លួន ឲ្យចេះគោរពឪពុកម្តាយ និង ឲ្យចេះដឹងទំនៀមទម្លាប់ប្រពៃណីខ្មែរជាដើម ជាពិសេស គេបាននាំកូនចូលសាលារៀន សិក្សាចំណេះវិជ្ជាផ្សេង ៗ ដើម្បីប្រយោជន៍ដល់ការចិញ្ចឹមជីវិត

របស់គេទៅអនាគត ឲ្យបានសុខសប្បាយ និង ថ្លៃថ្នូរ ។ ដោយមិនបានបង្អែបង្អង់ សមាគមខ្មែរយើង បានរួបរួមគ្នាកសាងវត្តអារាមឡើង ។ គ្រួសារខ្មែរយើង មានចិត្តសប្បាយរីករាយណាស់ បាននាំកូនចៅទៅវត្ត ដើម្បីធ្វើបុណ្យទានផង ដើម្បីឲ្យគេបានឃើញទំនៀមទម្លាប់ប្រពៃណី និង ពិធីសាសនារបស់ជាតិខ្លួនផង ។ សូមជម្រាបថា វត្តអារាមនេះហើយ ជាថ្នាលសំរាប់បណ្តុះបណ្តាល ការពារ កសាង វប្បធម៌ ប្រពៃណី និង សាសនារបស់ជាតិខ្មែរយើង ។ ហេតុនេះ គ្រួសារខ្មែរយើង ត្រូវតែនាំកូនចៅទៅវត្ត និងត្រូវតែជួយឧបត្ថម្ភ កសាង ថែរក្សា ការពារ វត្តអារាមរបស់ខ្មែរយើង ឲ្យបានល្អប្រពៃ តយូរអង្វែងទៅ ៕

**ចម្លើយ** (លោកស្រី ឌុក វ៉ាស៊ី) ការអប់រំមានពីរយ៉ាង : ១-អប់រំឲ្យកូនព្យាយាមរៀនសូត្រ ឲ្យកូនយល់ពីចំណេះវិជ្ជា ជាប្រភពនៃទ្រព្យសម្បត្តិរបស់មនុស្ស, ២-អប់រំទៅតាមទំនៀមទម្លាប់ប្រពៃណី កាន់ខ្ជាប់នូវវិន័យសីលធម៌ មានឥរិយាបថ មានមារយាទថ្លៃថ្នូរ ។

**យោបល់** (លោក ស៊ុយ ស៊ាងហេង)

**កូនជាទំពាំងស្នងឫស្សី** គឺ កូនចេះ កូនដឹង កូនមានជីវភាពត្រឹមត្រូវ កូនមានសីលធម៌ មានចរិយាល្អ ចេះថែរក្សាវប្បធម៌

ទំនៀមទម្លាប់ប្រពៃណី និង ប្រទេសជាតិមាតុភូមិ បានគង់វង្ស ។ ដូច្នេះ ដើម្បីនឹងបានកូនយ៉ាងនេះ មាតាបិតា ត្រូវមានចំណេះសំខាន់ ២ យ៉ាងគឺ : ១-ត្រូវចេះកសាងខ្លួនឲ្យល្អជាមុន ជាគម្រូរបស់កូន គឺចេះស្វែងយល់ និង សិក្សាចំណេះវិជ្ជាផ្សេង ៗ អ្វីដែលគួរចេះ ចាប់តាំងពីម្ហូបចំណីជាដើម ត្រូវតែរៀនឲ្យចេះ ចេះអ្វីចេះឲ្យប្រាកដ ចេះរៀបចំតុបតែងផ្ទះសម្បែង ចេះទាក់ទងរាក់ទាក់ញាតិមិត្រ ឬ ភ្ញៀវឲ្យបានល្អ ជាពិសេស ចេះទុកដាក់ខ្លួនឯង ជាមនុស្សល្អ ដូចធម៌លោកថា វិជ្ជាចរណសម្បន្នោ ជាអ្នកដល់ព្រមដោយវិជ្ជា និង ចរណៈ (ចរិយា) ។ ២-ចេះប្រដៅកូន គឺមិនមែនមានមាត់ហើយចេះតែថាទេ មិនអាងថាខ្លួនជាឪពុកម្ដាយហើយចេះតែប្រដៅគេទេ ធ្វើអ្វី និយាយអ្វី ត្រូវគិតពិចារណា ឲ្យម៉ត់ចត់ ត្រូវស្គាល់សិទ្ធិសេរីភាព ស្គាល់ កាលៈ ទេសៈ ស្រុកទេសគេយ៉ាងម៉េច សម័យនេះយ៉ាងម៉េច មិនមែនចេះតែតឹង តឹងទាល់តែដាច់ មិនមែនចេះតែធូរ ចេះតែបណ្ដោយទាល់តែខូច ។ យើងត្រូវដើរផ្លូវកណ្ដាល គឺ មជ្ឈិមាបដិបទា ត្រូវមានបញ្ញា មានមធ្យោបាយ មិនមែនចង់នាំគេទៅទីណា ហើយទាញគេកាត់តម្រង់ភ្លាមទេ ត្រូវចេះពន្យល់ រឿង កម្ម ផល ខ្ជិល ឧស្សាហ៍... រឿងសេពគប់ ពាលបណ្ឌិត រឿងអបាយមុខ រឿងទុំមុនស្រគាលសប្បាយខុសវ័យ ភ្លេចរៀនសូត្រជាដើម ត្រូវពន្យល់គេឲ្យច្បាស់

ទុកឱកាសឲ្យគេគិតពិចារណាខ្លួនគេផង ។

យើងជាឪពុក ម្ដាយ ត្រូវចេះដើរតួ ពេលណាដើរតួជាឪពុក ម្ដាយ ពេលណា ដើរតួជាគ្រូ ពេលណា ដើរតួជាទីប្រឹក្សា ពេលណា ដើរតួជាមិត្រសម្លាញ់... របស់កូន ។ ប្រការសំខាន់ កុំទុកឲ្យវាផុះខ្លួនវាតាមចិត្ត ដោយភ្លេចនាទីយើងជា ឪពុក ម្ដាយ កុំចង់ចេញផ្កាផ្លែ ជំនួសវា ទុកឲ្យវាចេញខ្លួនវា ដោយយើងគ្រាន់តែជួយជ្រួយដី ដាក់ជីរ ស្រោចទឹក ឲ្យសមល្មមប៉ុណ្ណោះ បានហើយ ៕

# ភាគបន្ថែម

៙❀៚

## ការសង្កេត

### របស់ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ

### ១-សិទ្ធិរបស់ស្ត្រីខ្មែរ

ក្នុងអតីតកាល ដែលស្ត្រីពិភពលោក មិនទាន់មានអ្វីនៅឡើយ ពេលនោះ ស្រីខ្មែរ មានសិទ្ធិដណ្ដឹងប្រុសយកមកធ្វើប្ដី មានសិទ្ធិដឹកនាំគ្រួសារ មានសិទ្ធិរហូតដល់ឡើងសោយរាជ្យ ជាស្ដេច គ្រប់គ្រងប្រទេសជាតិ ។ នេះ ជាចំណុចផ្ដួចផ្ដើមសំខាន់មួយ ក្នុងបណ្ដាចំណុចសំខាន់ជាច្រើន ដែលខ្មែរយើងត្រូវយល់និងមានមោទនភាព ។ សូមជម្រាបថា ជាតិជិតខាង មិនទាន់មានសូម្បីតែអក្សរ ខ្មែរយើង មានអក្សរ មានប្រឡាយទឹក មានផ្លូវគមនាគមន៍ មានសាលាឆទាន មានមន្ទីរពេទ្យមនុស្ស ពេទ្យ-សត្វ មានប្រាង្គប្រាសាទ រួចអស់ហើយ ។ មានច្រើនណាស់... មានមុនគេ ។

ចាប់ពីសតវត្សរ៍ ទី ១៤ មក សិទ្ធិរបស់ស្ត្រីខ្មែរ បានចុះទាបយ៉ាងខ្លាំង គួរឲ្យស្ដាយ ។ លុះដល់សតវត្សរ៍ ទី ១៩ ទើបស្ត្រីខ្មែរមានសិទ្ធិខ្លះៗ ឡើងវិញ... ។ ប៉ុន្តែ ក្នុងសម័យ ហ៊ុន សែន សព្វ

ថ្ងៃនេះ គេធ្វើបាបស្រី ៗ ច្រើនណាស់ គេចាក់ទឹកអាស៊ីដ គេបាញ់សម្លាប់ នាង ពិសិដ្ឋ ពិលីការ ជាដើម ដោយមិនមានរកខុសត្រូវអ្វីទាំងអស់ និង ស្រី ៗ ទៅជា ស្រីពេស្យា រាប់ម៉ឺន សែននាក់ ទាំងនៅក្នុងប្រទេស ទាំងចេញទៅក្រៅប្រទេស ។ គ្រួសារខ្មែរ ដាច់ដោចអស់ហើយ គ្រួសារខ្មែរ ខ្ទាចផ្សាយយំលែងចេញទឹកភ្នែកហើយ។ តើខ្មែរយើង ដឹងឬទេ ? យល់ឬទេ ? គិតយ៉ាងម៉េចដែរ ? នរណារៀបចំផែនការនេះ ? នេះ ជាល្បិចមួយ ដែលគេរំលាយជាតិខ្មែរ រំលាយវប្បធម៌ខ្មែរ រំលាយសាសនាខ្មែរ ។ ព្រះសង្ឃគ្រហស្ថ បងប្អូនរួមជាតិទាំងអស់គ្នា គប្បីភ្ញាក់រលឹក ដឹងខ្លួនឡើងរួបរួមសាមគ្គីគ្នា ការពារ កសាង វប្បធម៌ ជាតិ សាសនា របស់យើងឲ្យថ្កុំថ្កើង រុងរឿង ឡើងវិញ ជាប្រញាប់ កុំបីបង្អង់ ឡើយ ។

## ២-សិទ្ធិស្ត្រីទូទៅក្នុងពិភពលោក

ស្ត្រីទូទៅ សព្វថ្ងៃនេះ មានសិទ្ធិជិតស្មើនឹងបុរសហើយ ។ តើ សិទ្ធិនេះ បានមកពីណា ? ព្រះជាម្ចាស់ ប្រទានឬ ? អត់ទេ ។ គឺ ពិតជាបានមកពីកម្ម (អំពើ ឬ ការងារ) ។ កម្ម គឺ ការប្រឹងប្រែងទាមទារ តស៊ូ យ៉ាងស្វិតស្វាញ របស់ពួកស្រី ៗ ។ ក្នុងរឿងនេះស្រី ៗ ជាតិបារាំង បានខិតខំតស៊ូយ៉ាងច្រើន គួរឲ្យសរសើរ ។ ហេតុនេះ ស្ត្រីទូទៅក្នុងពិភពលោក ត្រូវតែក្រោកឡើង ទាមទារ

តស៊ូ តទៅទៀត ។ ឯ ប្រុស ។ ដែលមានសប្បុរសធម៌ ត្រូវតែចូលរួមជួយស្រី ។ ផងដែរ ។

រឿងមួយទៀត ខ្ញុំ អាត្មា សុំស្នើឲ្យជួយគិតពិចារណាសាឡើងវិញ ។ តាមធម្មតា ប្រុស ។ ច្រើនតែខិលខូច ចេះរកឧបាយល្បួងលោមបោកបញ្ឆោតស្រី ។ ប៉ុន្តែ ស្រី ។ ក៏ណាស់ដែរ ចេះតែបើកជន្ទួជន្ទេញប្រុស ។ (យកសាំងដាក់ជិតភ្លើង) ថែមទៀត[៨] ។ ហេតុនេះ ស្រី ។ ឬ សមាគមស្រី ។ គប្បីអប់រំគ្នាឲ្យមែនទែន ឬ គួរបង្កើត ច្បាប់ វិន័យ ឬ ប្រពៃណី ដាក់ទោស បន្ទោកបន្ទាបលែងរាប់អាន ស្រីណាដែលប្រព្រឹត្តផ្តេសផ្តាស ខុសចាកគន្លងធម៌ល្អរបស់ស្រី និង លើកតម្កើងស្រីណាដែលមានចរិយាល្អ ឲ្យរឹតតែខ្ពង់ខ្ពស់ត្រដែតឡើងទៀត ។ ចំណែកឯប្រុស ។ ខិលខូច (ច្រើនតែអ្នកធំ ។ ឬ អ្នកមាន) មិនត្រូវរួចខ្លួនទេ រដ្ឋ ត្រូវតែយកអ្នកនោះទៅធ្វើទោសទណ្ឌ តាមច្បាប់ជាធរមាន ឲ្យបានជាក់ស្តែងជាទីបំផុត ៕

---

[៨]-តាមធម្មតា សត្វញី ធម្មជាតិ មិនតែងខ្លួនឲ្យល្អទេ ប៉ុន្តែ ស្រី ។ មិនតែងខ្លួនត្រឹមតែល្អទេ វាហួសល្អទៅទៀត បានជាត្រូវពួកប្រុស ។ ពាល គេយកទៅធ្វើបាប ថោកទាបជាងសត្វទៅទៀត ។

## ៣-សិទ្ធិស្ត្រី ក្នុងពុទ្ធសាសនា

អ្នកខ្លះរិះគន់ថា ព្រះពុទ្ធ បន្ថោកបន្ទាបស្ត្រី ក្នុងរឿងសុំបួស ។ ឧទាហរណ៍ ព្រះនាងបជាបតីគោតមី ជាព្រះមាតុច្ឆា ចូលគាល់ព្រះពុទ្ធ ទូលសុំបួស ។ ព្រះពុទ្ធ ហាមឃាត់ថា កុំឡើយ ៣ ដង ។ ព្រះអានន្ទ ជួយទូលសុំឲ្យព្រះនាង... ចូលបួស ។ ព្រះអង្គ ទ្រង់ហាមឃាត់ ៣ ដងទៀត ។ ទើបព្រះអានន្ទ ទូលសួរថា ស្ត្រី បើបានបួសហើយ តើអាចសម្រេច សោតា សកទាគា អនាគា អរហត្តផល បាន ឬ ទេ ? ព្រះពុទ្ធ ត្រាស់ថា អាចសម្រេចមគ្គ ផល បាន ។ ព្រះអានន្ទ ទូលថា បើដូច្នោះ សូមព្រះអង្គមេត្តាអនុញ្ញាតឲ្យព្រះនាងបជាបតី បួសទៅ ។ ព្រះពុទ្ធ ទ្រង់ត្រាស់ថា បើព្រះនាង- អាចបដិបត្តិ គោរពគរុធម៌ ៨ ប្រការបាន ការគោរពនោះ ទុកជា ឧបសម្បទា របស់ព្រះនាងហើយ ។ គរុធម៌ ៨ ប្រការ គឺ :

១-ភិក្ខុនី សូម្បីបួសបាន ១០០ វស្សាហើយ ក៏ត្រូវតែគោរពភិក្ខុដែលទើបនឹងបួសថ្មីដែរ ។

២-ភិក្ខុនី មិនត្រូវនៅចាំវស្សា ក្នុងវត្តដែលមិនមានភិក្ខុទេ។

៣-ភិក្ខុនី ត្រូវសួរឧបោសថ និង ស្តាប់ឱវាទ ក្នុងសំណាក់ភិក្ខុសង្ឃ រៀងរាល់កន្លះខែ ។

៤-ភិក្ខុនី នៅចាំវស្សាហើយ ពេលចេញវស្សា ត្រូវបវារណា

ក្នុងសំណាក់សង្ឃទាំងពីរ ។

៥-ភិក្ខុនី បើត្រូវគរុកាបត្តិ ត្រូវប្រព្រឹត្ត បក្ខមានត្ត ក្នុងសំណាក់សង្ឃទាំងពីរ ។

៦-ភិក្ខុនី មុននឹងចូលបួស ត្រូវជាសិក្ខមានា បដិបត្តិ សិក្ខាបទ ៦ ចាប់តាំងពី បាណាតិបាត រហូត វិកាល អស់រយៈពេល២ឆ្នាំសិន ទើបអាចចូលបួសក្នុងសំណាក់សង្ឃទាំងពីរបាន ។

៧-ភិក្ខុនី មិនគប្បី ជេរ ប្រមាថ ភិក្ខុ ទេ ។

៨-ភិក្ខុនី មិនគប្បី ប្រៀនប្រដៅ ភិក្ខុ ទេ ប៉ុន្តែ ភិក្ខុ គប្បី ប្រៀនប្រដៅ ភិក្ខុនី បាន ។

ព្រះនាងបជាបតី គោតមី ព្រមគោរពតាម គរុធម៌ ៨ ប្រការនេះ ឧបសម្បទា របស់ព្រះនាង ក៏សម្រេចដោយការគោរពនោះ[៩]។ ឯ សិក្ខាបទ ភិក្ខុមានត្រឹមតែ ២២៧ ទេ ប៉ុន្តែ ភិក្ខុនីមានសិក្ខាបទ រហូតដល់ ៣១១ ៕

ការរិះគន់នេះ បើនិយាយតាមសម័យបច្ចុប្បន្ន ទុកជាការសមរម្យដែរ ប៉ុន្តែ បើគិតដល់អតីតកាលនោះវិញ ពេលនោះគ្មានច្បាប់ជាតិណា សាសនាណា ទោះជានៅប្រទេសឥណ្ឌាក្តី ប្រទេសចិនក្តី គេឲ្យតម្លៃទៅស្ត្រី សោះឡើយ ។

---

[៩]-វិន័យបិដក ចុល្លវគ្គ ១១-១៧៧-២៦១

មានតែ ពុទ្ធសាសនា មួយប៉ុណ្ណោះទេ ដែលប្រៀនប្រដៅឲ្យប្តីប្រពន្ធ គោរពគ្នាទៅវិញទៅមក និង បើកសិទ្ធិឲ្យស្ត្រីៗ បដិបត្តិតាមពុទ្ធសាសនាជាភេទគ្រហស្ថ បានស្មើនឹងបុរសដែរ ។ ឯភេទជាអ្នកបួសវិញ មានការតឹងតែង និង បញ្ញត្ត សិក្ខាបទ ច្រើនជាងគ្នាខ្លះមែន ក៏ដើម្បីជួយការពារសន្តិសុខដល់ភេទជាស្ត្រី តែប៉ុណ្ណោះ ។

ម្យ៉ាងទៀត សព្វថ្ងៃនេះ មានអ្នកខ្លះ គេចង់ឲ្យមានភិក្ខុនីឡើងវិញ ។ តើរឿងនេះ យ៉ាងម៉េចដែរ ? បើនិយាយតាមក្បួនច្បាប់ យើងមិនអាចដោះស្រាយចេញទេ ព្រោះវិន័យ ព្រះពុទ្ធបានបញ្ញត្តទុករួចអស់ហើយ ។ ឥឡូវនេះ ឧបជ្ឈាយ៍ ភិក្ខុនី អស់ហើយ គណៈសង្ឃភិក្ខុនី ក៏អស់ហើយដែរ តើយើងបួសដោយវិធីយ៉ាងដូចម្តេច ? បើវាអស់គ្រាប់ពូជទៅហើយ វាអស់មេអ្នកបង្កើតទៅហើយ ។ នរណាអ្នកបំបួស នរនោះ ដើររំលងវិន័យ អ្នកបួសខុសវិន័យ មិនមែនជាភិក្ខុនី ត្រឹមត្រូវតាមធម៌វិន័យ របស់ព្រះពុទ្ធសាសនា ទេ គឺជាភិក្ខុនី បែបថ្មី របស់ឧបជ្ឈាយ៍ថ្មី ដែលតាំងខ្លួនស្រដៀង នឹងជាព្រះពុទ្ធថ្មី ដូច្នោះដែរ តើព្រះសង្ឃណាអាចទទួលយល់ព្រមផង ។

អ្នកខ្លះថា មហាយាន គេនៅមានភិក្ខុនី ។ យើងទៅចម្លងភិក្ខុនី ពីគេមក ។ សូមជម្រាបថា មហាយាន គេបានកែប្រែធម៌វិន័យ អស់ច្រើនណាស់ ។ ភិក្ខុនី របស់មហាយាន មិនមែន

ដូចភិក្ខុនី ក្នុងសម័យពុទ្ធកាលទេ ។ តើយើងយកភិក្ខុនី មហាយាន មករួមជាមួយភិក្ខុហិនយាន (ថេរវាទ) ម្ខាងគោ ម្ខាងក្របី ដូច្នេះឬ ? ធម៌ចម្លងចូលគ្នា បានងាយ ប៉ុន្តែ វិន័យ រួមចូលគ្នា មិនបានងាយទេ ។ បើវិន័យមិនស្មើគ្នា មិនអាចធ្វើសង្ឃកម្ម ជាមួយគ្នាបានទេ ។ ហេតុនេះ យើងមិនគប្បីចម្លងភិក្ខុនី ពីគេមកទេ ។ មើលទម្រង់គេ ហើយរៀបចំ បង្កើត របស់យើង សមរម្យជាង ៕

ខ្ញុំ អាត្មា យល់ឃើញថា យើងមិនគប្បីដើរផ្លូវទាំងពីរខាងលើនេះទេ យើងត្រូវតែដើរផ្លូវកណ្ដាល យកលំនាំភិក្ខុនី ខ្លះ ៗ មកអនុវត្ត ដើម្បីបំបួសស្រី ៗ ជា សីលវតី (អ្នកមានសីលធម៌) ខ្ពស់ជាងឧបាសិកា ប៉ុន្តែ មិនមែនជាភិក្ខុនី ទេ ។ សូមបញ្ជាក់ថា បានបុណ្យកុសល ឬ សម្រេច មគ្គ ផល ដោយសារការបដិបត្តិ កំចាត់កិលេស... មិនមែនដោយសារឈ្មោះ ភិក្ខុនី ឬ សីលវតី ទេ ។ ខ្ញុំ អាត្មា បានចាប់ផ្ដើមបំបួសខ្លះ ៗ ហើយ ។

ដើម្បីឲ្យបានឯកភាព គណៈសង្ឃ មានសម្ដេច សង្ឃរាជជាប្រធាន និង ក្រសួងធម្មការ គប្បីប្រជុំគ្នាតាក់តែងច្បាប់ រៀបចំរឿងនេះ ឲ្យបានល្អសមរម្យ ថ្លៃថ្នូរ ជាមង្គលដ៏បវរក្នុងពុទ្ធសាសនាតរៀងទៅ(១០) ៕ ល៕

---

(១០)- ប៉ុន្តែ កុំបើកឲ្យប្រសេចប្រសាច ដូចភិក្ខុ សព្វថ្ងៃនេះ ។

# វជិរាសូត្រ

៙❀៚

ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន ។ វជិរាភិក្ខុនីអង្គុយចំរើនធម៌ ក្រោមម្លប់ឈើ ក្នុងព្រៃអន្ធវ័ន ។ មារមានចិត្តបាបពោលឡើងថា-

កេនាយំ បកតោ សត្តោ
ក្វចិ សត្តស្ស ការកោ
ក្វចិ សត្តោ សមុប្បន្នោ
ក្វចិ សត្តោ និរុជ្ឈតិ ៕

សត្វនេះ បុគ្គលណា បង្កើតឡើង បុគ្គលអ្នកបង្កើតសត្វស្ថិតនៅក្នុងទីណា សត្វកើតឡើងក្នុងទីណា សត្វរលត់ទៅក្នុងទីណា។

លំដាប់នោះ វជិរាភិក្ខុនី ពោលឡើងថា-

កឹ នុ សត្តោតិ បច្ចេតិ
មារ ទិដ្ឋិគតំ នុ តេ
សុទ្ធសង្ខារបុញ្ជោយំ
នយិធ សត្តុបលព្ភតិ ៕
យថា ហិ អង្គសម្ភារា
ហោតិ សទ្ទោ រថោ ឥតិ
ឯវំ ខន្ធេសុ សន្តេសុ
ហោតិ សត្តោតិ សម្មតិ ៕

ទុក្ខមេវ ហិ សម្ភោតិ
ទុក្ខំ តិដ្ឋតិ វេតិ ច
នាញ្ញត្រ ទុក្ខា សម្ភោតិ
នាញ្ញត្រ ទុក្ខា និរុជ្ឈតិ ៦

ម្នាលមារ ទិដ្ឋិរបស់អ្នក យល់ថា សត្វមែនឬ ? នេះជាគំនរនៃសង្ខារសុទ្ធទេ ក្នុងគំនរនៃសង្ខារសុទ្ធនេះ អ្នករកសត្វមិនឃើញឡើយ ។ ដូចស័ព្ទ (ពាក្យ) ដែលបានឈ្មោះថា រថដូច្នេះ កើតឡើងបាន ព្រោះសម្ភារៈជាអង្គប្រកប យ៉ាងណាមិញ កាលបើខន្ធទាំងឡាយមានហើយ ការសន្មតថា សត្វដូច្នេះក៏មានយ៉ាងនោះឯង ។ ព្រោះថា ទុក្ខកើតឡើងផង ទុក្ខស្ថិតនៅផង ទុក្ខរលត់ទៅផង ក្រៅពីទុក្ខ គ្មានអ្វីកើត ក្រៅពីទុក្ខ គ្មានអ្វីរលត់ទេ ។

លំដាប់នោះ មារមានចិត្តបាប អាក់អន់ចិត្ត អន្តរធានបាត់ទៅ[១១] ៕

សង្កេត :

នេះ ជាបញ្ហារបស់ស្រីម្នាក់ គឺ វជិរាភិក្ខុនី ។ បញ្ហានេះ រាក់ ឬ ជ្រៅ លោក អ្នក យល់បានឬទេ ?

---

[១១]-សុត្តន្តបិដក សំយុត្តនិកាយ វជិរាសូត្រ ៣០-៣១-២០

បើនិយាយតាមការសន្មត សត្វ ឬ មនុស្ស មាន ប៉ុន្តែ បើនិយាយតាមបរមត្ថ សត្វ ឬ មនុស្ស មិនមានទេ មានតែសង្ខារធម៌ប៉ុណ្ណោះ ។ សង្ខារធម៌ មានលក្ខណៈយ៉ាងនេះ គេសន្មតថាសត្វ សង្ខារធម៌ មានលក្ខណៈយ៉ាងនោះ គេសន្មតថា មនុស្ស ។ សម្ភារៈប្រកបចូលគ្នា មានលក្ខណៈយ៉ាងនេះ គេហៅថា រថ (រទេះ) សម្ភារៈប្រកបចូលគ្នា មានលក្ខណៈយ៉ាងនោះ គេហៅថា តុ ទូ ។ តាមបរមត្ថ មិនមាន សត្វ មនុស្ស រទេះ តុ ទូ ជាដើមទេ មានតែសង្ខារធម៌ ឬ ធាតុផ្សេង ៗ រួមផ្សំគ្នាប៉ុណ្ណោះ ។

សង្ខារធម៌ទាំងឡាយ មានលក្ខណៈ ជា អនិច្ចំ ទុក្ខំ អនត្តា ជាធម្មតា មិនមានសង្ខារណាមួយទៀងទាត់ ស្ថិតស្ថេរទេ ដូច្នេះសង្ខារធម៌មួយ ៗ គឺ ជាដុំទុក្ខមួយ ៗ ព្រោះហេតុនោះ ទើប វជិរាភិក្ខុនី ពោលឡើងថា ទុក្ខកើតឡើងផង ទុក្ខស្ថិតនៅផង ទុក្ខរលត់ទៅផង ក្រៅពីទុក្ខ គ្មានអ្វីកើត ក្រៅពីទុក្ខ គ្មានអ្វីស្ថិតនៅ ក្រៅពីទុក្ខ គ្មានអ្វីរលត់ទៅ ៕

អត់ត្រូវការទេ ទុកនាំមានបញ្ហា ត្រូវតែសម្លាប់ចោល ។ នាង កុណ្ឌលកេសី គិតថា អញមានបញ្ញា ដែរ ត្រូវតែយកបញ្ញាមក ដោះស្រាយ ទើបនិយាយថា បង តាំងពីខ្ញុំកើតដឹងក្តីមក ខ្ញុំ មិន ដែលស្រឡាញ់ប្រុសណាទេ ស្រឡាញ់តែបងមួយប៉ុណ្ណោះ ខ្ញុំ នឹង លែងបានជួបបងទៀតហើយ ថ្ងៃនេះ មុននឹងខ្ញុំស្លាប់ ខ្ញុំសូម រាំច្រៀងកៀកកើយបងឲ្យអស់ចិត្តជាទីបំផុត ។ ចោរ ឆ្លើយថា នាងចង់ធ្វើអ្វី ចូរធ្វើឲ្យអស់ចិត្តនាងចុះ ។ នាង ក៏ចាប់រាំច្រៀង ប្រកៀកប្រកើយ ហើយឆ្លៀតឱកាសដែលចោរភ្លេចខ្លួន ក៏ច្រាន ចោរនោះទម្លាក់ជ្រោះស្លាប់ទៅ ។ ទេវតា លើកំពូលភ្នំ ឃើញ ហេតុការណ៍នោះ ពោលឡើងថា -

**ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ**
**ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ១**
**ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ**
**ឥត្ថីបិ បណ្ឌិតា ហោតិ លហុំ អត្ថំ វិចិន្តិតា ១**

ប្រុសមិនមែនឈ្មោះថាបណ្ឌិត ក្នុងហេតុទាំងអស់ទេ សូម្បីស្រី អ្នកមានឧបាយវាងវៃ ក្នុងហេតុនោះ ៗ ក៏ឈ្មោះថាបណ្ឌិត ដែរ ។

ប្រុសមិនមែនឈ្មោះថា បណ្ឌិត ក្នុងហេតុទាំងអស់ទេ សូម្បីស្រីអ្នក ត្រិះរិះឃើញប្រយោជន៍យ៉ាងរហ័ស ក៏ឈ្មោះថា បណ្ឌិតដែរ ។

ក្រោយពីចោរស្លាប់ហើយ ដោយក្រែងមាតាបិតាបន្ទោស នាងកុណ្ឌលកេសី មិនត្រឡប់ចូលផ្ទះវិញទេ ចេះតែដើរ ៗ ទៅបានជួបនឹងអាស្រមរបស់ពួកបរិព្វាជក អ្នកបួសស្លៀកពាក់ ស ទើបចូលទៅសុំបួសក្នុងសំណាក់នោះ ។ នាងបានរៀនធម៌សព្វគ្រប់ក្នុងលទ្ធិនោះ ។ ថ្ងៃមួយ នាងកំពុងអង្គុយចំរើនធម៌ មានឆ្កែមួយបានពាំកដៃសាកសពមនុស្ស មកទម្លាក់ចោលជិតនាង នាងក៏បានឃើញអសុភនិមិត្ត ពេញដោយដង្កូវ ក្នុងសាកសពនោះ កើតសេចក្តីសង្វេគ ហើយសាកសួរសហធម្មិកទាំងឡាយ គ្មាននរណាដឹង គេប្រាប់ថា ចូរនាងទៅសាកសួរសាវ័ករបស់ព្រះពុទ្ធចុះ ។ នាង បានចូលទៅជួបជាមួយនឹងសាវករបស់ព្រះពុទ្ធ សាវករបស់ព្រះពុទ្ធបាននាំនាងទៅគាល់ព្រះសម្មាសម្ពុទ្ធ ។ ព្រះសម្មាសម្ពុទ្ធ បានសម្តែងធម៌ ខន្ធ ធាតុ អាយតនៈ ជាធម្មជាតិមិនស្អាតផង មិនទៀងផង ជាទុក្ខផង ជាអនត្តាផង ។ លុះបានស្តាប់ធម៌នេះហើយ នាងបានសម្រេចសោតាបត្តិផល ទើបសុំបព្វជ្ជា ឧបសម្បទា ។ ព្រះភគវា ទ្រង់ប្រទានបំបួសជា ឯហិភិក្ខុនី ។

លុះបួសហើយ នាងបានដឹងនូវការកើត និង ការរលត់ នៃសង្ខារទាំងឡាយ ដោយគ្រាន់តែបានឃើញទឹកលាងជើងបន្តិច ក៏គិតថា សង្ខារទាំងឡាយ ទាំងពួង ក៏មានលក្ខណៈដូច្នោះដែរ ។ ចិត្តរបស់នាង ក៏រួចផុតចាក អាសវៈ មិនមានតណ្ហា ឧបាទាន

ដោយប្រការទាំងពួង ។ ព្រះពុទ្ធ បានតែងតាំង ភិក្ខុនី អង្គនេះ ជាឯតទគ្គៈ អ្នកត្រាស់ដឹងរហ័ស (ខិប្បាភិញ្ញា) ប្រកបដោយវិជ្ជាព្រមទាំង បដិសម្ភិទា ដោយសព្វគ្រប់[១២] ៕

សង្កេត :

១-នាងកុណ្ឌលកេសី មានបញ្ញាផង មានបញ្ញារហ័សផង បើមានតែបញ្ញា ហើយយឺត ប្រហែលជាមិនរួចខ្លួនទេពេលហ្នឹង ។ ព្រោះហេតុនោះ ត្រូវមានបញ្ញាច្រើនប្រការ ទើបជាការប្រសើរ ។

ខ្ញុំ អាត្មា ធ្លាប់និយាយប្រាប់ថា ខ្មែរយើង ធ្លាប់ឱទានថា អុញ ចាញ់បោកគេ (ឬយួន) ទៀតហើយ ។ ពាក្យថា អុញ... មួយម៉ាត់នេះ បើរឿងប្រវត្តិសាស្ត្រ កាត់តម្លៃមិនបានទេ ថ្លៃណាស់ អស់តម្លៃច្រើនណាស់ ។ យើងត្រូវមានបញ្ញាឲ្យឆាប់រហ័ស កុំឲ្យចាញ់បោកគេដដែលៗទៀត ។ សព្វថ្ងៃនេះ ខ្មែរយើងចាញ់បោកគេឬទេ ? ខ្មែរយើងមានបញ្ញាយឺតច្រើនគ្នាណាស់ ចូរខំប្រឹងឡើង គប្បីជួយគ្នាឡើង ។

២-នាងកុណ្ឌលកេសី មុននឹងបានសម្រេច មគ្គ ផល នាង

---

[១២]-សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ៧៦-២១-១១៨

និង អដ្ឋកថា ធម្មបទ ប៉ុន្តែ ត្រូវយកគម្ពីរព្រះត្រៃបិដក ជាគោល ៕

បានសម្លាប់ប្តី (ចោរ) ដោយចេតនា ។ បើនាងខ្វាចបាបជ្រុល ប្រហែលជាស្លាប់ខ្លួន ខានបានសម្រេច មគ្គ ផល ហើយ ។ ខ្មែរយើងអ្នកធ្មេចភ្នែក ហើយស្រែកថា បាប ។ ហ្នឹងច្រើនណាស់ មិនព្រមយកបញ្ញាមកប្រើដូចនាង កុណ្ឌលកេសី ទេ ។ ព្រះពុទ្ធ មិនដែលបង្រៀនឲ្យសាវកមានសទ្ធា ប្រាសចាកបញ្ញាទេ ។ ខ្ញុំ អាត្មា មិនប្រាថ្នាដើរជាមួយនឹងពុទ្ធបរិស័ទ អ្នកមានសទ្ធា ហើយធ្មេចភ្នែកទេ ៕

# គូនៃស្វាមីភរិយា មាន ៤ យ៉ាង

៣✵៧

១-ឆវោ ឆវាយ សទ្ធឹ សំវសតិ ប្រុសខ្មោច នៅរួមជាមួយស្រីខ្មោច ។

២-ឆវោ ទេវិយា សទ្ធឹ សំវសតិ ប្រុសខ្មោច នៅរួមជាមួយស្រីទេវតា ។

៣-ទេវោ ឆវាយ សទ្ធឹ សំវសតិ ប្រុសទេវតា នៅរួមជាមួយស្រីខ្មោច ។

៤-ទេវោ ទេវិយា សទ្ធឹ សំវសតិ ប្រុសទេវតា នៅរួមជាមួយស្រីទេវតា [១៣] ៕

<u>សង្កេត</u> :

ក្នុងទីនេះ មនុស្សអាក្រក់ គ្មានសីលធម៌ ព្រះពុទ្ធ ហៅថា ខ្មោច មនុស្សល្អ មានសីលធម៌ ព្រះពុទ្ធ ហៅថា ទេវតា ។ ដូច្នេះ យើងឃើញថា ប្រុសក៏អាចទៅជាខ្មោច ឬ ជាទេវតា បាន ស្រីក៏អាចទៅជាខ្មោច ឬ ជាទេវតា បានដូចគ្នា ស្មើគ្នាដោយការបដិបត្តិ មិនមាននរណា វិសេសជាងនរណា ដោយកំណើតទេ ៕

---

[១៣]-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២-៥៤-១៤០

**៤-ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ** តាំងស្រ្តី ឬ បុរស អ្នកទ្រុស្តសីល ឲ្យជាអធិបតី ៕

## ត្រកូលមានទ្រព្យសម្បត្តិច្រើន

ឋិតថេរនៅបានយូរ ព្រោះហេតុ ៤ ប្រការ

**១-នដ្ឋំ គវេសន្តិ** ស្វែងរករបស់ដែលបាត់

**២-ជិណ្ណំ បដិសង្ខរោន្តិ** ជួសជុលរបស់ដែលចាស់គ្រាំគ្រា

**៣-បរិមិតបានភោជនា ហោន្តិ** មានបាយ និង ទឹកជាដើម ស្គាល់ប្រមាណ ។

**៤-សីលវន្តំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ** តាំងស្រ្តី ឬ បុរស អ្នកមានសីល (សីលធម៏) ឲ្យជាអធិបតី [១៥] ។

## ទ្រព្យសម្បត្តិដែលគេរកបានមកហើយ

គប្បីចែកជា ៤ ចំណែក

**១-ឯកេន ភោគេ ភុញ្ជេយ្យ** សំរាប់បរិភោគ ១ ចំណែក

**២-៣- ទ្វីហិ កម្មំ បយោជយេ** សំរាប់ប្រកបការងារ ២ចំណែក

---

(១៥)- សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣-១០៨-២៧០

៤-ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ បុរស អ្នកទ្រុស្តសីល ឲ្យជាអធិបតី ៕

## ត្រកូលមានទ្រព្យសម្បត្តិច្រើន

ឋិតថេរនៅបានយូរ ព្រោះហេតុ៤ប្រការ

១-នដ្ឋំ គវេសន្តិ ស្វែងរករបស់ដែលបាត់

២-ជិណ្ណំ បដិសង្ខរោន្តិ ជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣-បរិមិតបានភោជនា ហោន្តិ មានបាយ និង ទឹកជាដើម ស្គាល់ប្រមាណ ។

៤-សីលវន្តំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ បុរស អ្នកមានសីល (សីលធម៌) ឲ្យជាអធិបតី [១៥] ។

## ទ្រព្យសម្បត្តិដែលគេរកបានមកហើយ

គប្បីចែកជា៤ចំណែក

១-ឯកេន ភោគេ ភុញ្ជេយ្យ សំរាប់បរិភោគ ១ ចំណែក

២-៣- ទ្វីហិ កម្មំ បយោជយេ សំរាប់ប្រកបការងារ ២ចំណែក

---

[១៥]- សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣-១០៨-២៧០

៤-ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ បុរស អ្នកទ្រុស្តសីល ឲ្យជាអធិបតី ៕

## ត្រកូលមានទ្រព្យសម្បត្តិច្រើន

ឋិតថេរនៅបានយូរ ព្រោះហេតុ ៤ ប្រការ

១-នដ្ឋំ គវេសន្តិ ស្វែងរករបស់ដែលបាត់

២-ជិណ្ណំ បដិសង្ខរោន្តិ ជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣-បរិមិតបានភោជនា ហោន្តិ មានបាយ និង ទឹកជាដើម ស្គាល់ប្រមាណ ។

៤-សីលវន្តំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ បុរស អ្នកមានសីល (សីលធម៌) ឲ្យជាអធិបតី [១៥] ។

## ទ្រព្យសម្បត្តិដែលគេរកបានមកហើយ

គប្បីចែកជា ៤ ចំណែក

១-ឯកេន ភោគេ ភុញ្ជេយ្យ សំរាប់បរិភោគ ១ ចំណែក

២-៣- ទ្វីហិ កម្មំ បយោជយេ សំរាប់ប្រកបការងារ ២ចំណែក

---

(១៥)- សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣-១០៨-២៧០

# គូនៃស្វាមីភរិយា មាន ៤ យ៉ាង

១-ឆវោ ឆវាយ សទ្ធឹ សំវសតិ បុរុសខ្មោច នៅរួមជាមួយស្រីខ្មោច ។

២-ឆវោ ទេវិយា សទ្ធឹ សំវសតិ បុរុសខ្មោច នៅរួមជាមួយស្រីទេវតា ។

៣-ទេវោ ឆវាយ សទ្ធឹ សំវសតិ បុរុសទេវតា នៅរួមជាមួយស្រីខ្មោច ។

៤-ទេវោ ទេវិយា សទ្ធឹ សំវសតិ បុរុសទេវតា នៅរួមជាមួយស្រីទេវតា [១៣] ៕

<u>សង្កេត</u> :

ក្នុងទីនេះ មនុស្សអាក្រក់ គ្មានសីលធម៌ ព្រះពុទ្ធ ហៅថា ខ្មោច មនុស្សល្អ មានសីលធម៌ ព្រះពុទ្ធ ហៅថា ទេវតា ។ ដូច្នេះ យើងឃើញថា បុរុសក៏អាចទៅជាខ្មោច ឬ ជាទេវតា បាន ស្រីក៏អាចទៅជាខ្មោច ឬ ជាទេវតា បានដូចគ្នា ស្មើគ្នាដោយការបដិបត្តិ មិនមាននរណា វិសេសជាងនរណា ដោយកំណើតទេ ៕

---

[១៣]-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២-៥៤-១៤០

## ភរិយា ៧ ពួក

៙✻៚

១-វធកសមា ភរិយា ភរិយាស្មើដោយអ្នកសម្លាប់ (ពេជ្ឈឃាត)

២-ចោរសមា ភរិយា ភរិយាស្មើដោយចោរ

៣-អយ្យសមា ភរិយា ភរិយាស្មើដោយម្ចាស់ (ចៅហ្វាយ)

៤-មាតុសមា ភរិយា ភរិយាស្មើដោយមាតា

៥-ភគិនិសមា ភរិយា ភរិយាស្មើដោយប្អូនស្រី

៦-សខីសមា ភរិយា ភរិយាស្មើដោយសំឡាញ់

៧-ទាសិសមា ភរិយា ភរិយាស្មើដោយខ្ញុំស្រី ៕

ព្រះមានព្រះភាគ និមន្តទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋី បានឮសម្លេងមនុស្សនិយាយគ្នាទ្រហឹងអឺងកង ត្រាស់សួរថា សម្លេងអ្វីខ្លាំងម្ល៉េះ ដូចជាសម្លេងពួកអ្នកចាប់ត្រី ។ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា នាងសុជាតា នេះ ជាកូនប្រសាររបស់ខ្ញុំព្រះអង្គ បាននាំមកអំពីត្រកូលស្តុកស្តម្ភ ។ នាងនេះ មិនចេះស្តាប់ មិនចេះគោរពអ្នកណាទេ ។ ព្រះមានព្រះភាគ ត្រាស់ឲ្យហៅនាងសុជាតាចូលមកគាល់ លុះមកដល់ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះអង្គសម្តែងអំពីភរិយា ៧ ពួក ហើយត្រាស់សួរថា នាងជាភរិយាប្រភេទណា ? នាងសុជាតា ស្តាប់មិនសូវយល់ ទើបសូម ព្រះ

ទសពល មេត្តាអធិប្បាយពង្រីកសេចក្តី ឲ្យពិស្តារ លុះ ព្រះសាស្តា សម្តែងធម៌ចប់ នាងសុជាតា ក្រាបទូលថា សូមព្រះអង្គ សំគាល់ ទុកនូវខ្ញុំព្រះករុណា ថាជា ភរិយាស្មើដោយខ្ញុំស្រី ចាប់ដើមអំពី ថ្ងៃនេះតទៅ [១៤] ។

<u>សង្កេត</u> :

ក្នុងទីនេះ ព្រះពុទ្ធ មិនបានសម្តែងអំពីស្វាមី ទេ ព្រោះ មិនមែនជាឱកាសដែលត្រូវសម្តែង ប៉ុន្តែ ដោយហេតុផលហើយ យើងគប្បីយល់ថា ស្រី ប្រុស ក៏មានល្អ មានអាក្រក់ដូចគ្នា ស្មើគ្នា ដូច្នេះ ស្វាមី ក៏ត្រូវមាន ៧ ពួក ដូចភរិយាដែរ គ្រាន់តែកែសម្រួល តាមអត្ថន័យរបស់បុរសតែប៉ុណ្ណោះ ។

## ត្រកូលមានទ្រព្យសម្បត្តិច្រើន
### មិនឋិតថេរនៅបានយូរ ព្រោះហេតុ ៤ ប្រការ

១-នដ្ឋំ ន គវេសន្តិ មិនស្វែងរករបស់ដែលបាត់

២-ជិណ្ណំ ន បដិសង្ខរោន្តិ មិនជួសជុលរបស់ចាស់គ្រាំគ្រា

៣-អបរិមិតបានភោជនា ហោន្តិ មានបាយ និង ទឹក (ហូបចុក) ជាដើម មិនស្គាល់ប្រមាណ ។

---

[១៤]- សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៧-៦០-១៦៧

៤-ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ បុរស អ្នកទ្រុស្តសីល ឲ្យជាអធិបតី ៕

## ត្រកូលមានទ្រព្យសម្បត្តិច្រើន
### ឋិតថេរនៅបានយូរ ព្រោះហេតុ ៤ ប្រការ

១-នដ្ឋំ គវេសន្តិ ស្វែងរករបស់ដែលបាត់

២-ជិណ្ណំ បដិសង្ខរោន្តិ ជួសជុលរបស់ដែលចាស់គ្រាំគ្រា

៣-បរិមិតបានភោជនា ហោន្តិ មានបាយ និង ទឹកជាដើម ស្គាល់ប្រមាណ ។

៤-សីលវន្តំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ តាំងស្ត្រី ឬ បុរស អ្នកមានសីល (សីលធម៌) ឲ្យជាអធិបតី [១៥] ។

## ទ្រព្យសម្បត្តិដែលគេរកបានមកហើយ
### គប្បីចែកជា ៤ ចំណែក

១-ឯកេន ភោគេ ភុញ្ជេយ្យ សំរាប់បរិភោគ ១ ចំណែក

២-៣- ទ្វីហិ កម្មំ បយោជយេ សំរាប់ប្រកបការងារ ២ចំណែក

---

(១៥)- សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣-១០៨-២៧០

៣-ទន្តស្សេវ ទាតព្វំ គប្បីឲ្យដល់អ្នកដែលឲ្យវិញ

៤-អទន្តស្ស ន ទាតព្វំ កុំគប្បីឲ្យដល់អ្នកដែលមិន-ឲ្យវិញ

៥-ទន្តស្សបិ អទន្តស្សបិ ទាតព្វំ ឲ្យវិញក្តី មិនឲ្យវិញក្តី ត្រូវតែឲ្យ

៦-សុខំ និសីទិតព្វំ គប្បីអង្គុយឲ្យសុខ

៧-សុខំ ភុញ្ជិតព្វំ គប្បីបរិភោគឲ្យសុខ

៨-សុខំ និបជ្ជិតព្វំ គប្បីដេកឲ្យសុខ

៩-អគ្គិ បរិចរិតព្វោ គប្បីបម្រើភ្លើង

១០-អន្តោ ទេវតា នមស្សិតព្វា គប្បីគោរពទេវតាខាងក្នុង[១៧] ។

## អធិប្បាយ

❋❋❋

រឿងក្តៅ រឿងឆេះ ទុកជាភ្លើង ដូច្នេះ កុំនាំភ្លើងក្នុងផ្ទះចេញក្រៅ និង កុំនាំភ្លើងក្រៅផ្ទះចូលក្នុង ។ គប្បីឲ្យដល់អ្នកដែលឲ្យ កុំគប្បីឲ្យដល់អ្នកដែលមិនឲ្យវិញ បានសេចក្តីថា បើគេខ្ចីអ្វី

---

[១៧]-អដ្ឋកថា ធម្មបទ ភាគ ៣.

ហើយគេសងវិញ គប្បីឲ្យខ្ចី បើគេខ្ចីអ្វីហើយគេមិនសងវិញទេ កុំគប្បីឲ្យខ្ចីទៀត ។ ឲ្យវិញក្តី មិនឲ្យវិញក្តី ត្រូវតែឲ្យ បាន សេចក្តីថា ញាតិអ្នកទ័លក្រក្តី អ្នកកំសត់ទុរគតក្តី ត្រូវតែឲ្យ ត្រូវតែសង្គ្រោះ កុំគិតចង់បានអ្វីពីគេវិញ ។ គប្បីអង្គុយឲ្យសុខ គឺចេះអង្គុយ មិនជិតពេក មិនឆ្ងាយពេក មិនអង្គុយតាមផ្លូវ រវល់តែទើស ក្រោកមិនឈប់ជាដើម ។ គប្បីបរិភោគឲ្យសុខ គឺចេះទទួលទាន ទទួលទានប៉ុន្មាន លៃទុកប៉ុន្មាន ទទួលទានមុន ឬទទួលទានក្រោយ ជាដើម ។ គប្បីដេកឲ្យសុខ គឺចេះដេក ដេកមុន ឬ ដេកក្រោយ មុនដេកមើលទុកដាក់សព្វគ្រប់ហើយឬនៅ ។ គប្បីបម្រើភ្លើង បានសេចក្តីថា ឪពុកក្មេក ម្តាយក្មេក និង ប្តី ប្រៀបដូចភ្លើង បើចេះប្រើ ឬ ចេះបម្រើ រមែងបានប្រយោជន៍ បានការកក់ក្តៅ បានពន្លឺ... បើមិនចេះប្រើ ឬ មិនចេះបម្រើ អាចរលាក ឬ ឆេះផ្ទះ ក៏បាន ដូច្នេះ គប្បីបម្រើឲ្យល្អ ។ ឪពុកក្មេក ម្តាយក្មេក និង ប្តី ទុកជាទេវតាក្នុងផ្ទះដូច្នេះ គប្បីគោរពទេវតាខាងក្នុងឲ្យបានល្អ ។ ក្នុងសង្គម សព្វថ្ងៃនេះ អ្នកណាឲ្យប្រយោជន៍គេ គេទុកជាទេវតាទាំងអស់ តាមភោជនីយដ្ឋានក្តី អាកាសយានដ្ឋានក្តី គេគោរពភ្ញៀវ គោរពអ្នកដំណើរ ដូចជាទេវតា ៕

# លោក អ្នក សប្បុរស ដែលជួយឧបត្ថម្ភការបោះពុម្ព

| | |
|---|---|
| ១-ឧបាសិកា គីម មួយ | ១០០០ € |
| ២-ឧបាសក ឡុក ប៊ុនអ៊ីវ ឧបាសិកា តាន់ ស៊ីវឡាង | ២០០ € |
| ៣-លោក និង លោកស្រី ហាក់ ព្រួ | ៥០ € |
| ៤-Mr. et Mme Henry IAN | ៥០០ € |
| ៥-ឧបាសក តាន់ ណាំ | ៥០ € |
| ៦-លោក និង លោកស្រី មឿង ភោគ | ១២០ € |
| ៧-លោក ឡុង ចានលី អ្នកស្រី លីម ឆេងប៉ូ | ១០០ € |
| ៨-លោក តាន់ ថាយ | ២៥ € |
| ៩-Mrs Tann Pheng Leng Rina | ៥០ € |
| ១០-Mrs Tann Pheng Sim | ២០ € |
| ១១-ឧបាសិកា ង៉ាន់ គិមលុន | ១០០ € |
| ១២-ឧបាសិកា គឹម សួផន និង កូនចៅ | ២០ € |
| ១៣-លោក ឡៅ សារុន និង ភរិយា | ១០០ € |
| ១៤-ឧបាសិកា នេត្រ គួន | ២០ € |
| ១៥-ឧបាសិកា នៅ ទាវ ខេង និង កូនចៅ | ២០ € |
| ១៦-ឧបាសិកា អៀង ហុង | ២០ € |
| ១៧-ឧបាសិកា ប៊ុន ហ៊ុលឃុត | ៣០ € |
| ១៨-លោក ណុប ពុទ្ធីរ៍ ព្រមទាំងគ្រួសារ | ១០០ € |
| ១៩-លោក យី សេងឡុង និង ភរិយា | ៤០ € |

២០-លោក លីម ហ៊ុយគៀង អ្នកស្រី ម៉ៅ ទៀង ១០០ $

២១-អាចារ្យ មិន ធូ ឧបាសិកា តាំង វួចចៅ ១០០ €

២២-ឧបាសិកា ឈា ឡេងហាក់ ១០០ $

២៣-លោក អ៊ុំង ភីរុន អ្នកស្រី អ៊ុំង គឹមវឿន ៣០ €

២៤-ឧបាសក ស៊ា ខៃអ៊ាន ឧបាសិកា ឡៅ គីម ហ៊្កិច ១០០ €

២៥-លោក យុន សារុន អ្នកស្រី ឌី ស៊ីលៀប និង កូន ៥០ €

២៦-ឧបាសិកា ថ្វាង អាង ២០ €

២៧-លោក ខៀវ ឡេង និង ភរិយា ២០ €

២៨-អ្នកគ្រូ ឡុង ឡី ២០ €

២៩-លោក មាស សួផាន់ និង ភរិយា ២០ €

៣០-លោកយាយ គាវ ៣០ €

៣១-Mr et Mme IM Oeun Jean ១០០ €

៣២-លោក ប៊ុន ធី ៣០ €

៣៣-ក្រុមវេនបិណ្ឌ ឧបាសិកា មួន សារ៉ាត ៤០ €

៣៤-ឧបាសិកា គុល ទូច ១០០ €

៣៥-ឧបាសិកា ចាន់ ហឿន និង កូនចៅ ១០០ $

៣៦-ឧបាសក ង្វី ហុក ឧបាសិកា ឡោត កិណ្ណរី និង កូនចៅ ២០ €

៣៧-ឧបាសក គង់ គិន ឧបាសិកា វ៉ាន់ សាក់ ២០ €

៣៨-ឧបាសិកា ជីប ហុងយេន ១៥ €

៣៩-ឧបាសិកា អួន ២០ €

៤០-ឧបាសិកា ឆេង ២០ €

៤១-លោក តុង សេង អ្នកស្រី សុគន្ធ ២០ €

៤២-ឧបាសក តាន់ អ៊ាងហោ និង គ្រួសារ ១០ €

៤៣-ឧបាសិកា យី ខុន ១០ €

៤៤-អ្នកស្រី គីម គឹម ១០ €

៤៥-លោក និង អ្នកស្រី ផាយ វ៉ាន ២០ €

៤៦-គ្រួសារ ជៀវ ស៊ាងឡុន ២០ €

៤៧-លោក និង អ្នកស្រី គឹក សាន់ដេត ២០ €

៤៨-ឧបាសិកា ណៃម លិមអ៊ាន ២០ €

៤៩-ឧបាសិកា ណៃម លិមអ៊ុន ២០ €

៥០-លោក និង អ្នកស្រី សាយ សាវ៉ាត ៥០ €

៥១-លោក សេង ទាម ២០ €

៥២-ឧបាសិកា អាត អេង ២០ €

៥៣-ឧបាសិកា សេក ហេង ២០ €

៥៤-Mme et Mr. Kheng Jean ១០០ €

៥៥-ក្រុមវេនបិណ្ឌ ឧបាសិកា អេង ឡាំ ១០០ €

៥៦-ឧបាសិកា ម៉ា វណ្ណា ៥០ €

៥៧-Mme Chrea Sinân et ses enfant ១០០ €

៥៨-Mme Chrea Livy et ses enfant ១០០ €

៥៩-ប៉ិច ប៊ុន លឿង ឈឿ ៥០ €

៦០-កញ្ញា ញាណ វ៉ាន់នី ២០ €

៦១-ឧបាសិកា កៅ លឹបសួផា ៣០ €

| | |
|---|---|
| ៦២-ឧបាសិកា ទេស ពៅ | ៣០ € |
| ៦៣-ឧបាសិកា យក់ លាន | ២០ € |
| ៦៤-អ្នកស្រី គង់ គិន | ២០ € |
| ៦៥-អ្នកស្រី លឹម គីម ស្រ៊ាន | ២០ € |
| ៦៦-ឧបាសក ហៀង ហ៊ោ | ២០ € |
| ៦៧-ឧបាសិកា ពៅ គាតស្វី | ២០ € |
| ៦៨-ឧបាសិកា អ៊ុយ សុផល | ១០ € |
| ៦៩-ឧបាសិកា ជ្រាំ អាណា | ១០ € |
| ៧០-ឧបាសក អ៊ិន សារេន និង ភរិយា | ២០ € |
| ៧១-ឧបាសិកា សួស សុភាព | ២០ € |
| ៧២-M. IN DANA | ៥ € |
| ៧៣-M. IN DANO | ៥ € |
| ៧៤-Mlle IN DANEA | ៥ € |
| ៧៥-Mlle IN MADA | ៥ € |
| ៧៦-លោក ថោង ស៊ីម៉ង់ និង ភរិយា | ១០ € |
| ៧៧-ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ក្រិត្យនារី | ២០ € |
| ៧៨-ឧបាសិកា ជូ ម៉ាក់ | ២០ € |
| ៧៩-ឧបាសិកា អ៊ុក សារ៉េត | ២០ € |
| ៨០-លោក និង លោកស្រី ស្លូង ណារឿន | ២០ € |
| ៨១-លោកស្រី អ៊ួ ស៊ុម ស៊ីវតេង | ២០ € |
| ៨២-ឧបាសិកា ទី វណ្ណហង្ស | ១០ € |

៨៣-អ្នកស្រី អ៊ា ទុង ហ្វង និង បុត្រធីតា ៥០ €

៨៤-ឧបាសិកា ឃិន ហុកទីវ ១៥ €

៨៥-ឧបាសិកា សុត សុផានី ១៥ €

៨៦-ឧបាសិកា សៀប គិមហ៊ាង ១៥ €

៨៧-ឧបាសិកា ទា គីមលី ១៥ €

៨៨-ឧបាសិកា ទា គីមលន់ ១៥ €

៨៩-លោក និង អ្នកស្រី ស៊ាម ហ៊ុច ១៥ €

៩០-អាចារ្យ ញាណ ឆាន និង ភរិយា ១៥ €

៩១-ឧបាសក ឡៅ ហេង ឧបាសិកា តាន់ សាយយុត ១៥ €

៩២-ឧបាសិកា ឡៅ សាយឃីម ១៥ €

៩៣-លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ €

៩៤-អ្នកស្រី ឡៅ ហុងស៊ីម និង បុត្រធីតា ១៥ €

៩៥-ផុង ស្វនីថា និង ស៊ុន ណារ៉េត ១៥ €

៩៦-ឧបាសិកា ញ៉ឹក សាយ៉ាន់ ១៥ €

៩៧-ឧបាសិកា តេង សម្បត្តិ ២០ €

៩៨-ឧបាសិកា អ៊ុំ យន ១៥ €

៩៩-ឧបាសិកា ឡាយ សេងហាក់ ២០ €

១០០- ភិក្ខុ ជិន ភេន ៥០ €

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះ លោក អ្នក ដ៏មានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និង ញាតិកាសាលោហិត មិត្រសំឡាញ់ ជាដើម។ សូមលោក អ្នក ដ៏មានគុណទាំងឡាយជាដើមនោះ អនុមោទនា ចំពោះបុណ្យកុសលនេះ ហើយទទួលយក នូវឥដ្ឋមនុញ្ញផល ជាទីគាប់ចិត្ត កុំបីអាក់ខានឡើយ ៕ល៚

អត្តា ហវេ ជិតំ សេយ្យោ

ឈ្នះខ្លួនឯង ប្រសើរជាង ឈ្នះអ្នកដទៃ ។

La conquête de soi-même est meilleure que celle des autres hommes.

It is better to conquer oneself than to conquer other people.

# ស្រីជាមាតាពិភពលោក

៣✵៧

ស្រីជាមាតាពិភពលោក ប្រុសច្រើនគរគោកមិនគិតគន់
គិតត្រឹមថាស្រីជាប្រពន្ធ បម្រើតាមគុណរបស់ប្រុស ។
ធ្វើអ្វីតាមចិត្តមិនគិតគួរ អាណិតអាសូរដល់ស្រីសោះ
ឲ្យធ្វើការផ្ទះឥតចន្លោះ ឯកិត្តិយសគ្មានសោះឡើយ ។
តាមពិតពួកយើងទាំងអស់គ្នា បានកើតមកជាមនុស្សហើយ
ដោយសារស្រីៗណាអ្នកអើយ តើហេតុម្ដេចឡើយភ្លេចគុណគេ ។
កើតមុនដំបូងជាទារក ដេកនឹងលាមកមិនដឹងទេ
តើបានអ្នកណាចិញ្ចឹមគេ ថ្នាក់ថ្នមបំពេថៃគ្រប់មុខ ។
អ្នកនោះគឺពិតជាស្រីហើយ ធ្វើការឥតស្បើយឲ្យកូនសុខ
ទោះបីពិបាក ឬ ស្រណុក មាតាចេញមុខធ្វើសព្វគ្រប់ ។
បើឮកូនយំនៅពេលថ្ងៃ ឬមានទុក្ខភ័យនៅពេលយប់
ម្ដាយស្ទុះទៅភ្លាមឥតឈរឈប់ មើលសព្វមើលគ្រប់ជួយស្ងួនភ្ងា ។
គុណនៃមាតាមានច្រើនពេក អនន្តអនេកនឹងពណ៌នា
ចូរកូនប្រុសស្រីទាំងអស់គ្នា គោរពបូជាកុំភ្លេចគុណ ។
ប្រុសឃើញស្រី ។ កុំមើលងាយ ត្រូវនឹកដល់ម្ដាយទុកជាមុន
ព្រោះស្រីនេះហើយអ្នកមានគុណ កូនកើតលើសលន់ពេញលោកា ។